# ប្រជុំកខធម៌

## សង្ខេប

## ជំនួយដល់សាលាធម្មវិន័យ

## ថ្នាក់ត្រី- ទោ- ឯក

## និង ធម្មថិក អត្ថ ថ្មី

រៀបរៀងដោយ

**យិន - វន់**

លេខ៥៥, វិថី ប៉ាស្ទ័រភ្នំពេញ

# ប្រជុំកងធម៌

# សង្ខេប

ឧបត្ថម្ភធម្មវិន័យគ្រប់ផ្នាក់

និង

អង្គធម្មកថិក

ការផ្សាយរបស់

លេខ ៥៥ វិថី ប៉ាស្ទ័រ ភ្នំពេញ

និពន្ធដោយបណ្ឌិត

ឃិន - វន់

## ប្រជុំកថធម៌សង្ខេប

### ទុកៈពួក២

### ធម៌មានឧបការៈច្រើន ២ យ៉ាង

១- សតិ *សេចក្ដីរលឹកបាន,*

២- សម្បជញ្ញៈ *សេចក្ដីដឹងខ្លួន ។*

### ធម៌ជាលោកបាល គ្រប់គ្រងរក្សាលោក ២ យ៉ាង

១- ហិរិ *សេចក្ដីខ្មាស់បាប,*

២- ឱត្តប្បៈ *សេចក្ដីក្រែងខ្លាចបាប ។*

### ធម៌ធ្វើឱ្យល្អ ២ យ៉ាង

១- ខន្តី *សេចក្ដីអត់ធន់,*

២- សោរច្ចៈ *សេចក្ដីស្ងប់ស្ងៀម ។*

### បុគ្គលរកបានដោយកម្រ ២ យ៉ាង

១- បុព្វការី *អ្នកធ្វើឧបការៈមុន,*

២- កតញ្ញូកតវេទី *អ្នកដឹងឧបការៈដែលលោកធ្វើហើយធ្វើតបវិញ ។*

### ពួកកាយវជ៍

## ធម៌ ២ យ៉ាង (៩)

១- កុសលធម៌ ធម៌ជាកុសល,

២- អកុសលធម៌ ធម៌ជាអកុសល ។

## ធម៌ ២ យ៉ាង (៩)

១- លោកិយធម៌ ធម៌ជាវិស័យនៃលោកជាបុថុជ្ជន,

២- លោកុត្តរធម៌ ធម៌ដែលផុតវិស័យនៃលោកជាបុថុជ្ជន ។

## ធម៌ ២ យ៉ាង (៩)

១- សង្ខតធម៌ ធម៌ដែលមានបច្ច័យប្រជុំតាក់តែង ,

២- អសង្ខតធម៌ ធម៌ដែលមិនមានបច្ច័យប្រជុំតាក់តែង ។

## ធម៌ ២ យ៉ាង (៩)

១- រូបធម៌ សភាវៈដែលមានរូប បានដល់រូបខន្ធ

២- អរូបធម៌ សភាវៈដែលមិនមានរូបបានដល់រូបខន្ធគឺ

វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ វិញ្ញាណក្ខន្ធ ។

## បុគ្គល ២ ពួក គឺ

១- សេក្ខបុគ្គល បុគ្គលដែលនៅមានកិច្ចសិក្សាទៀត,

២- អសេក្ខបុគ្គល បុគ្គលដែលអស់កិច្ចសិក្សាហើយ ។



WAT KHEMARARATANARAM

# សង្ខារ ២ យ៉ាង

*សង្ខារ ប្រែថា ធម្មជាតិតាក់តែង បានដល់ការគិតដែល- កើតឡើងជាមួយចិត្ត ។*

១- ឧបាទិន្នកសង្ខារ *សង្ខារដែលមានវិញ្ញាណគ្រប់គ្រង*

២- អនុបាទិន្នកសង្ខា *សង្ខារដែលមិនមានវិញ្ញាណគ្រប់គ្រង ។*

# អំពីសីល

## សីលមានលក្ខណៈ ១ យ៉ាងគឺ

បតិដ្ឋានលក្ខណៈ មានកិរិយាតំកល់នៅជា « លក្ខណៈ » ។

## សីលមាន ២ យ៉ាង

១- និច្ចសីល បានដល់សីល ៥,

២- ឧបោសថសីល បានដល់សីល ៨ ។

## សីលមាន ២ យ៉ាង (៥)

១- ចារិត្តសីល សីលប្រព្រឹត្តតាមបញ្ញត្តិ,

២- វារិត្តសីល វៀរមិនធ្វើបំពានសីល, ហៅថាវិរតិសីលក៏បាន ។

## សីល ២ យ៉ាង (៥)

១- អភិសមាចារិកសីល មិនប្រព្រឹត្តកន្លងសិក្ខាបទតូចៗ,

២- អាទិព្រហ្មចរិយសីល ខាងដើមព្រហ្មចរិយគឺមិនប្រព្រឹត្តកន្លងសិក្ខាបទ ។

## សីល ២ យ៉ាង (៥)

១-វិរតិសីល សីលវៀរចាកទោស,

២- អវិរតិសីល សីលមិនវៀរចាកទោស ។

**សីល ២ យ៉ាង (៩)**

**១- ចេតនាសីល** សីលកើតឡើងដោយចេតនា ,

២- ញត្តិសីល សីលកើតឡើងដោយញត្តិចតុត្ថកម្មវាចា ។

**សីល ២ យ៉ាង (៩)**

**១- បរិយន្តសីល** សីលមានទីបំផុត,

**២- អបរិយន្តសីល** សីលមិនមានទីបំផុត ។

**សីល ២ យ៉ាង (៩)**

**១- និស្សិតសីល** សីលអាស្រ័យតណ្ហានិងទិដ្ឋិ ,

**២- អនិស្សិតសីល** សីលអាស្រ័យតណ្ហានិងទិដ្ឋិ ។

**សីល ២ យ៉ាង (៩)**

១- កាលបរិយន្តសីល សីលមានសមាទានមានកំណត់កាល,

២- អាបាណកោដិកសីល សីលមានជីវិតនៅទីបំផុតគឺរក្សាមិនឱ្យធ្លុះធ្លាយដរាបដល់អស់ជីវិត ។

**សីលដែលនឹងកើតឡើងដោយហេតុ ២ យ៉ាងគឺ ៖**

១- ហិរិ សេចក្ដីខ្មាសបាប ។

២- ឱត្តប្បៈ សេចក្ដីក្រែងខ្លាចបាប ។

## របងរបស់សីល ២ យ៉ាង

១- សីលសំវរៈ សង្រួមក្នុងសីល ,

២- សតិសំវរៈ សង្រួមសតិ ។

ធម៌ទាំងពីរនេះហៅថា ចំណីឧបោសថក៏បាន ។

## អំពីសីល ៣ យ៉ាង

១- និច្ចសីល បានដល់សីល ៥

២- ឧបោសថសីល បានដល់សីល ៨

៣- អតិរេកសីល បានដល់សីល ១០

សីលទាំង៣នេះឱ្យឈ្មោះថាសីលប៉ុណ្ណោះ ចំណែកសីល ៤ ឱ្យឈ្មោះថា អធិសីល គឺសីលជាន់ខ្ពស់ សីលនេះសម្រាប់ភិក្ខុ ។

## ឧបោសថសីលមានធម៌ជាកម្លាំង ២ យ៉ាងគឺៈ

១- សមថកម្មដ្ឋាន ២- វិបស្សនាកម្មដ្ឋាន ។

## ឧបោសថសីលមានធម៌ជាកល្យាណ ២ យ៉ាងគឺ

១- ធម្មស្សវនៈ ឧស្សាហ៍ស្ដាប់ធម៌,

២- វិបស្សនាភាវនា ចំរើនវិបស្សនា ។

## គ្រឿងផូរផង់របស់សីល ៣ យ៉ាង

១- អបិជ្ជោ សេចក្តីប្រាថ្នាតិច,
២- សន្តោសៈ សេចក្តីសន្តោស,
៣- សល្លេក្ខោ ជុសខាត់នូវកិលេសធម៌ ។

## លក្ខណៈរបស់សីលមាន ៣ យ៉ាងគឺ

១- សីលបតិដ្ឋានៈ មានកិរិយាតម្កល់នូវសីលជាលក្ខណៈ
២- ទុស្សីល្យវិធំសនដ្ឋានៈ មានកិរិយាកំចាត់បង់នូវបុគ្គលទ្រុស្ត-សីលជាលក្ខណៈ
៣- ឱត្តប្បញ្ញហិរិញ្ញេវបតិដ្ឋានៈ មានកិរិយាតម្កល់នូវហិរិនិងឱត្តប្បៈជាលក្ខណៈ ។

## វិរតិចេតនា ដែលឱ្យកើតសីលមាន ៣ យ៉ាងគឺ

១- សម្បត្តវិរតិ វៀរចាកវត្ថុដែលខ្លួនជួបប្រទះ,
២- សមាទានវិរតិ វៀរដោយអំណាចសមាទាន,
៣- សមុច្ឆេទវិរតិ វៀរដោយអំណាចនៃការលះកិលេស ។

## ប្រភេទរបស់សីល ៤ យ៉ាងគឺ

១- ចេតនា តាំងផ្ចិត្តវៀរគ្រប់សិក្ខាបទ,

២- បញ្ញា ប្រាជ្ញាពិចារណាឱ្យសព្វគ្រប់,

៣- អវិតិក្កមៈ កំចាត់បង់នូវទោសៈ,

៤- សំវរៈ សង្រួមក្នុងឥន្ទ្រីយ៍ទាំង១២ ខាងក្រៅ ។

## សីលមានអានុភាព ៤ យ៉ាង

១- ឧទកសរណាសីលគុណោ សីលមានអានុភាពត្រជាក់ដូចជាទឹក

២- ឧចោសថសមោសីលគុណោ សីលមានអានុភាពដូចជាថ្នាំឱសថ ,

៣- អាចារសមោសីលគុណោ សីលមានអានុភាពញុាំងអ្នករក្សាឱ្យប្រព្រឹត្តល្អ ,

៤- មណិសមោសីលគុណោ សីលមានអានុភាពដូចជាកែវមណី ។

## សីលសំដៅយកធម៌ ៤ គឺ

១- ចេតនា ២- ចេតសិក

៣- សំវរៈ ៤- អវិតិក្កម ។

(ទាំង៤នេះហៅថា អាយុរបស់សីលក៏បាន)

## សមុដ្ឋានរបស់សីល ៥ មាន ២ យ៉ាង

១- វចីភេទ បញ្ចេញវាចាសុភាពទន់ភ្លន់ចំពោះភិក្ខុ-សាមណេរ

២- ចេតនា តាំងចិត្តវៀរចាកគ្រប់សិក្ខាបទ ។

## សមុដ្ឋានសីល ៨ មាន ៣ យ៉ាងគឺ

១- ឧបោសថកាលេ រក្សាក្នុងកាលនៃថ្ងៃឧបោសថ,

២- វចីភេទ បញ្ចេញវាចាឱ្យច្បាស់លាស់,

៣- ចេតនា តាំងចិត្តវៀរចាកគ្រប់សិក្ខាបទ ។

## ធម៌ ៣ ប្រៀបធៀប

១- សីល ប្រៀបដូចជាដី, ២- វិបស្សនា ដូចជាថ្ម,

៣- បញ្ញា ដូចជាកាំបិត ។

## ឫសគល់របស់សីលមាន ២ យ៉ាងក៏មាន ៧ យ៉ាងក៏មាន

## មាន ២ យ៉ាងនោះគឺ៖

កាយ ១, វាចា ១,

## មាន ៧ យ៉ាងនោះគឺ ៖

កាយសុចរិត៣ វចីសុចរិត៤ ។

## សីល ៥ មានធម៌ជាកម្លាំង ៥ យ៉ាងគឺ

១- មេត្តា ២- សម្មាអាជីវៈ ៣- សន្តោស

៤- សច្ចៈ ៥- អប្បមាទៈ។

*អាសនៈរបស់សីលមានតែមួយ គឺ មេត្តា ។*

## សីលបានសម្រេចផល ៣ យ៉ាង

១- សោតាបត្តិផល, ២- សកិទាគាមិផល

៣- អនាគាមិផល, និងមគ្គ ១ ខាងលើគឺ អរហាត្តមគ្គ។

សីល ‹សីធាតុ + លុបច្ច័យ

ប្រែថា គ្រៀកនូវកុសល ។

ប្រែតាមអត្ថបាន ៥ យ៉ាងគឺ

១- សមោធារនត្ថោ ប្រែថា ប្រជុំនូវសុចរិត,

២- ឧបការនត្ថោ ប្រែថា ទ្រទ្រង់ឱ្យខ្ពង់ខ្ពស់,

៣- សីនត្ថោ ប្រែថា ចំរើន,

៤- សីលត្ថោ ប្រែថា ប្រក្រតី,

៥- សីតលត្ថោ ប្រែថា ត្រជាក់ ។

## អានិសង្សសីលមាន ៥ យ៉ាងគឺ

១- អប្បមាទោ ធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ អ្នកនោះនឹងបាននូវគំនរទ្រព្យដ៏ច្រើន មិនមានអធិករណ៍ ព្រោះសេចក្ដីមិនប្រមាទ,

២- កល្យាណោ កិត្តិសទ្ទោ អព្ភុច្ចតិ នឹងមានកេរ្តិ៍ឈ្មោះពីរោះល្អ ជាកល្យាណកិត្តិស័ព្ទ ផុសអណ្ដែតឡើង,

៣- វិសារទោ ឧបសង្កមិ អមង្កុភូតោ *កាលនឹងចូលទៅកាន់ទីប្រជុំ តែងរីករាយមិនមានអៀនអន់ដាក់មុខសំយុងចុះ,*

៤- អសម្មុឡ្ហោ កាលំ ករោតិ *វេលានឹងធ្វើកាលកិរិយា* មិន*វង្វេងស្មារតី,*

៥- កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ *បន្ទាប់អំពីការបែកធ្លាយខន្ធទៅ តែងបានទៅកើតសុគតិ ។*

ដំណឹងសៀវភៅបេញថ្មី

សៀវភៅអភិធម្មត្ថសង្គហសង្ខេប សម្រាប់ថ្នាក់ឯករៀបរៀងដោយមហា សោម-សុវណ្ណ, សៀវភៅជីវិតគ្រប់លក្ខណ៍រៀបរៀងដោយភិក្ខុធម្មបាលោ ខៀវ-ជុំ នឹងមានចេញលក់ក្នុងពេលឆាប់ៗ នេះ ។

## អំពីសទ្ធា

## សទ្ធាមាន ២ យ៉ាង

១- សទ្ធាលោកិយៈ ការជឿជាប់នៅក្នុងលោក ឬជឿប្រាស ចាកបញ្ញា,

២- សទ្ធាលោកុត្តរៈ ការជឿប្រកបដោយបញ្ញា, ឬជឿធ្ងន់ ផុតចាកលោក ។

## សទ្ធាលោកុត្តរៈ បែកបេញជា ៤ យ៉ាង

១- កម្មសទ្ធា ការជឿកម្ម,

២- វិបាកសទ្ធា ការជឿផលរបស់កម្ម,

៣- កម្មស្សកតាសទ្ធា ការជឿថាសត្វមានកម្ម ដែលខ្លួនធ្វើ ជារបស់ខ្លួន,

៤- តថាគតពោធិសទ្ធា ការជឿញាណរបស់ព្រះតថាគត ។

## សទ្ធាតែងកើតក្នុងចិត្តមាន ៥៧ គឺ

**កាមា**វចរសោភណៈ ២៤, រូបាវចរសោភណៈ ១៥

អរូបាវចរសោភណៈ ១២, លោកុត្តរៈ ៨ ។

## លក្ខណៈរបស់សទ្ធា

បសាទលក្ខណៈ មានសេចក្តីជ្រះថ្លាជាលក្ខណៈ

បែកចេញ ជា ២ យ៉ាង គឺ;

១- សម្បសាទលក្ខណា: គឺសេចក្តីជ្រះថ្លាជាលក្ខណ:,

២- បក្ខន្ទលក្ខណាសទ្ធា មានសេចក្តីជឿស្ទុះទៅខាងមុខ ។

## សទ្ធាមានលក្ខណា ២ យ៉ាង (៩)

១- សទ្ទហានលក្ខណាសទ្ធា មានសេចក្តីជឿជាលក្ខណ:,

២- ឱកប្បនលក្ខណាសទ្ធា មានកិរិយាស្ទង់មើលហេតុជាផល ហើយទើបធ្វើជាលក្ខណ: ។

## សទ្ធាបំរើនដោយធម៌ ២ យ៉ាង

១- អសទ្ធិន្ទ្រិយំ បជហន្តោ សទ្ធិន្ទ្រិយំ ភាវេតិ លះបង់សទ្ធាដោយចំរើនសទ្ធា ។

២- សទ្ធិន្ទ្រិយំ ភាវេន្តោ អសទ្ធិន្ទ្រិយំ បជហាតិ ចំរើនសទ្ធាលះបង់សទ្ធា ។

## អានិសង្សរបស់បុគ្គលមានសទ្ធា ៥ យ៉ាង

១- បឋមំ អនុកម្ពន្តិ កុលបុត្រអ្នកមានសទ្ធាព្រះតថាគតអនុគ្រោះមុនគេ,

២- បឋមំ ឧបសង្កមន្តិ ព្រះជាម្ចាស់ចូលទៅជិតមុនគេ,

៣- បឋមំ បដិគ្គណ្ហន្តិ ព្រះជាម្ចាស់ចូលទៅទទួលទានមុនគេ,

៤- បឋមំ ធម្មទេសនំ ព្រះជាម្ចាស់សម្ដែងធម៌ឱ្យស្ដាប់មុនគេ,

៥- សត្តលោកំ ឧបជ្ជតិ រមែងទៅកើតក្នុងទេវលោក គឺស្ថានសួគ៌ ។

## តថាគតពោធិសទ្ធាបែកចេញជា ២ យ៉ាង

១- កាលិកសទ្ធា ជឿក្នុងព្រះនាមទាំង ៩ មានអរហំជាដើម,

២- អកាលិកសទ្ធា ជឿក្នុងបារមីទាំង ១០ ។

## ការជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ៤ យ៉ាង

១- ពុទ្ធេ បសន្នា ជ្រះថ្លាចំពោះព្រះពុទ្ធ,

២- អដ្ឋង្គិកេ មគ្គេ បសន្នា ជ្រះថ្លាចំពោះអដ្ឋង្គិកមគ្គ ៨,

៣- វិរាគេ ធម្មេ បសន្នា ជ្រះថ្លាចំពោះព្រះធម៌ប្រាសចាក-រាគៈ គឺព្រះនិព្វាន,

៤- សង្ឃេ បសន្នា ជ្រះថ្លាចំពោះព្រះសង្ឃ ។

## ការហូរមកនៃបុណ្យ ៤ យ៉ាង

១- ពុទ្ធេ អវេច្ចប្បសាទេន ដោយសេចក្ដីជ្រះថ្លាមិនកក្រើកចំពោះព្រះពុទ្ធ,

២- ធម្មេ អវេច្ចប្បសាទេន ដោយសេចក្ដីជ្រះថ្លាមិនកក្រើកចំពោះព្រះធម៌,

៣- សង្ឃេ អវេច្ចប្បសាទេន ដោយសេចក្តីជ្រះថ្លាមិនកក្រើកចំពោះព្រះសង្ឃ,

៤- អរិយកន្តេហិ សីលេហិ ដោយសីលដែលព្រះអរិយលោកប្រាថ្នាគឺសីលមិនពពុះពពាល ។

## ធម៌ជាប្រទ្បាយ ៣ យ៉ាងគឺ

១- បសាទោ ជ្រះថ្លា,

២- សង្វេគោ តក់ស្លុត,

៣- តេសុចរិតា ប្រព្រឹត្តល្អដោយទ្វារទាំង ៣ ។

ធម៌ ៣ យ៉ាងនេះ ហៅថា ហេតុដែលនាំឱ្យកើតបុណ្យក៏បាន ។

## បុគ្គលប្រកបដោយធម៌ ៥ យ៉ាង
## នឹងបានទៅកើតក្នុងស្ថានសួគ៌

១- សទ្ធោ មានសទ្ធាគឺសេចក្តីជឿរបស់ដែលគួរជឿ,

២- ហិរិ មានហិរិគឺសេចក្តីខ្មាចនូវអំពើបាប,

៣- ឱតប្បី មានឱតប្បៈគឺសេចក្តីក្រែងខ្លាចនូវបាប,

៤- អារទ្ធវិរិយោ គឺមានសេចក្តីព្យាយាម,

៥- បញ្ញាវា          គឺមានបញ្ញាច្រើន ។

ធម៌៥យ៉ាងនេះអាចធ្វើឱ្យបុគ្គលឱ្យឋិតនៅក្នុងព្រះសទ្ធម្មឬ ៥យ៉ាងទៀតគឺ

សទ្ធា សីល      សុត្ត      ចាគ      បញ្ញា ។

**ដំណឹងសៀវភៅចេញថ្មី**

សៀវភៅអត្ថាធិប្បាយ   សាសនសុភាសិតថ្នាក់ទោ សៀវភៅប្រស្នាវិន័យសង្ខេប ( ផ្នែកសង្ឃកម្ម ) រៀបរៀង ដោយមហា សោម-សុវណ្ណា ។

សៀវភៅការប្រែលោតប្រយោគដោយជ្រើសរើស រៀបរៀងដោយបញ្ញា សោម-សម្បូណ៌ ។

# អំពីសរណគមន៍

## សរណគមន៍ ៣ យ៉ាង

១- ព្រះពុទ្ធ, ២- ព្រះធម៌, ៣- ព្រះសង្ឃ ។

**សរណគមន៍ទាំង ៣ នេះបើបែកមាន ២ យ៉ាង គឺ**

១- លោកុត្តរសរណគមន៍,

២- លោកិយសរណគមន៍,

លោកុត្តរសរណគមន៍ គឺសរណគមន៍ដែលឃើញនូវសច្ចៈ ៤ កំចាត់បង់នូវកិលេស មានព្រះនិព្វានជាអារម្មណ៍ បានដល់ព្រះអរិយបុគ្គលមានសោតាបន្នបុគ្គលជាដើម ។

លោកិយសរណគមន៍ គ្រាន់តែសង្កត់សង្កិននូវកិលេស មានសទ្ធានិងសម្មាទិដ្ឋិជាដើម, មានសទ្ធាជាឫស នឹងធ្វើទិដ្ឋិឱ្យត្រង់ក្នុងបុញ្ញកិរិយាវត្ថុ ១០ ដូច្នេះ ឈ្មោះថា លោកិយសរណគមន៍ ។

លោកិយសរណគមន៍នេះ សម្រេចដោយអាការៈ ៤ យ៉ាងគឺ

១- អត្តនិយ្យាតនៈ ប្រគល់កាយថ្វាយជីវិត ,

២- អត្តប្បាយនតា យកគុណព្រះរតនត្រៃជាទីពឹង ,

៣- សិស្សភាវូបគមនៈ ប្រគល់ខ្លួនជាសិស្ស ,

៤- ចាណិចាតៈ គោរពព្រះរតនត្រ័យដរាបអស់ជីវិត ។

# ប្រភេទសរណគមន៍មាន ៤ យ៉ាង

១- អត្តសន្និយ្យាតនៈ, ២- តប្បរាយនៈ

៣- សិស្សភាវៈ, ៤- ចាណិចាតបគមនៈ ។

# ឫសគល់របស់សរណគមន៍ ៣ យ៉ាង

១- សទ្ធា ២- ជីវិតបរិច្ចាគ ៣- បញ្ញា ។

# សរណគមន៍សៅហ្មងដោយហេតុ ៣ យ៉ាង

១- អញ្ញាណំ *មិនស្គាល់គុណព្រះរតត្រ័យ,*

២- សំសយំ *សង្ស័យក្នុងគុណព្រះរតណត្រ័យ,*

៣- មិច្ឆាញ្ញាណទស្សនំ *ឃើញខុសក្នុងគុណព្រះរតនត្រ័យ ។*


**ដំណឹងសៀវភៅចេញថ្មី**

សៀវភៅរឿងផែនដីស្រូបនូវជនប្រាំមួយនាក់ ដែលប្រព្រឹត្តក្នុងកម្មសម័យពុទ្ធកាល ។

រៀបរៀងដោយមហា សោម-សុវណ្ណ

# តិកៈ ពួក ៣

## រតនៈ ៣ យ៉ាង

*ព្រះពុទ្ធ ១ , ព្រះ ធម៌ ១, ព្រះសង្ឃ ១ ។*

## គុណរបស់ព្រះរតន ៣ យ៉ាង

១- *ព្រះពុទ្ធទ្រង់ត្រាស់ដឹងប្រពៃ ដោយព្រះអង្គឯងជាមុនហើយ ប្រដៅអ្នកដទៃឱ្យដឹងតាមផង ។*

២- *ព្រះធម៌រក្សាអ្នកប្រតិបត្តិ មិនឱ្យធ្លាក់ទៅក្នុងទីអាក្រក់,*

៣- *ព្រះសង្ឃលោកប្រតិបត្តិល្អ តាមពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយប្រដៅអ្នកដទៃឱ្យធ្វើតាមផង ។*

## អាការដែលព្រះពុទ្ធទ្រង់ប្រដៅ ៣ យ៉ាង

១- *អភិញ្ញាយៈ ទ្រង់ប្រដៅដើម្បីឱ្យអ្នកស្តាប់ដឹងពិតឃើញពិត ក្នុងធម៌ដែលគួរដឹងគួរឃើញ ។*

២- *សនិទានៈ ទ្រង់ប្រដៅមានហេតុ កាលអ្នកស្តាប់ត្រិះរិះតាម រមែងឃើញពិតបាន ។*

៣- *សប្បាដិហារ ទ្រង់ប្រដៅជាអស្ចារ្យ គឺកាលអ្នកស្តាប់ប្រ-តិបត្តិតាមរមែងបានសម្រេចប្រយោជន៍តាម*

គួរដល់សេចក្តីប្រតិបត្តិ ។

## ឱវាទរបស់ព្រះពុទ្ធ ៣ យ៉ាង

១- សព្វបាបស្ស អករណំ ការមិនឱ្យធ្វើបាបទាំងពួង គឺឱ្យវៀរចាកទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត ។

២- កុសលស្សូបសម្បទា ការញុាំងកុសលឱ្យដល់ព្រមគឺឱ្យប្រកបសុចរិត ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ។

៣- សចិត្តបរិយោទបនំ ការជម្រះចិត្តរបស់ខ្លួនឱ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត មានលោភៈ ទោសៈ មោហៈ ជាដើម ។

## ទុច្ចរិត ៣ យ៉ាង

១- កាយទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយកាយ,

២- វចីទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយវាចា,

៣- មនោទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយចិត្ត ។

## សុចរិត ៣ យ៉ាង

១- កាយសុចរិត ប្រព្រឹត្តល្អដោយកាយ,

២- វចីសុចរិត ប្រព្រឹត្តល្អដោយវាចា,

៣- មនោសុចរិត ប្រព្រឹត្តល្អដោយចិត្ត,

## អកុសលមូល ៣ យ៉ាង

១- លោភៈ ចង់បានមិនចេះស្កប់,

២- ទោសៈ គិតប្រទុស្តគេ,

៣- មោហៈ វង្វេងមិនដឹងការពិត ។

## កុសលមូល ៣ យ៉ាង

១- អលោភៈ មិនចង់បាន,

២- អទោសៈ មិនគិតប្រទុស្តគេ,

៣- អមោហៈ មិនវង្វេង ។

## សប្បុរិសប្បញ្ញត្តិ បញ្ញត្តិរបស់សប្បុរស ៣ យ៉ាង

១- ទានៈ ឱ្យវត្ថុរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់អ្នកដទៃ,

២- បព្វជ្ជា កាន់ភេទបួសដើម្បីជាឧបាយវៀរចាកកាម,

៣- មាតាបិតុបដ្ឋាន ប្រតិបត្តិមាតាបិតាតាមគន្លងធម៌ ។

## អបណ្ណកបដិបទា សេចក្តីប្រតិបត្តិមិនខុស ៣ យ៉ាង

១- ឥន្ទ្រិយសំវរៈ សង្រួមឥន្ទ្រិយទាំង ៦ គឺភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត, មិនឱ្យមានសោមនស្ស, ទោមនស្ស ក្នុងវេលាឃើញរូប, ឮសម្លេង, ធុំក្លិន, លិទ្ធរស,

កាយពាល់ត្រូវ, ដឹងធម្មារម្មណ៍ដោយចិត្ត,

២- ភោជនេមត្តញ្ញុតា ស្គាល់ប្រមាណក្នុងការបរិភោគ អាហារតែល្មមសមគួរ មិនច្រើនមិនតិច,

៣- ជាគរិយានុយោគ: ប្រកបព្យាយាមដើម្បីជម្រះចិត្ត ឱ្យបរិសុទ្ធហ្មត់ចត់ មិនឃើញដល់ការដេកច្រើន ។

## បុញ្ញកិរិយាវត្ថុ ៣ យ៉ាង

១- ទានមយ: បុណ្យសម្រេចដោយការបរិច្ចាគទាន,

២- សីលមយ: បុណ្យសម្រេចដោយការរក្សាសីល,

៣- ភាវនាមយ: បុណ្យសម្រេចដោយការចម្រើនភាវនា ។

## សាមញ្ញលក្ខណៈ ៣ យ៉ាង

១- អនិច្ចតា សភាពជារបស់មិនទៀង,

២- ទុក្ខតា សភាពជាទុក្ខ,

៣- អនត្តតា សភាពជារបស់មិនមែនខ្លួន ។

## ពួកវាយរង

## វ័យមាន ៣ យ៉ាង

១- បឋមវ័យ គឺរាប់ពី១ឆ្នាំទៅដល់ ៣៣ ឆ្នាំ

២- មជ្ឈិមវ័យ		*គឺរាប់ពីត្រឹម ៣៤ ដល់ ៦៤,*

៣- បច្ឆិមវ័យ		*រាប់អំពីត្រឹម ៦៥ ទៅរហូត ។*

លោភៈ	ទោសៈ	មោហៈ	*បែកខ្នែង*

## លោភៈ បែកខ្នែងជា ២ គឺ

១- មានៈ	២- ទិដ្ឋិ ។

## ទោសៈ បែកខ្នែងជា ៦ គឺ

១- ឥស្សា,	២- មច្ឆរិយៈ,	៣- ឧទ្ធច្ចៈ,

៤- មក្ខៈ,	៥- ថីនមិទ្ធៈ,	៦- កុក្កុច្ចៈ ។

## មោហៈ បែកខ្នែងជា ៣ យ៉ាង គឺ

១- អហិរិកំ, ២- អនោត្តប្បំ, ៣- ឧទ្ធច្ចំ ។

## មោហៈមានឫស ៤ យ៉ាងគឺ

១- ចិត្តស្ស អន្ធការលក្ខណោ *មានសភាពធ្វើឱ្យខ្វាក់នូវភ្នែកជាលក្ខណៈ,*

២- អសម្បដិវេធរសោ *មានកិរិយាមិនចាក់ធ្លុះចំពោះជានិច្ច,*

៣- អសម្មាបតិបត្តិ បច្ចុប្បដ្ឋានា *មានកិរិយាខុសជាផល,*

៤- អយោនិសោមនសិការប្បទដ្ឋានោ *មានកិរិយា*

មិនធ្វើទុកក្នុងចិត្តជាលក្ខណៈ ។

## លក្ខណៈមិនក្រោធ ៤ យ៉ាង គឺ

១- នអក្កោច្ឆិ មិនជេរគេវិញ,

២- នអវធិ មិនប្រទុស្តពាយគេវិញ,

៣- នអជិនិ មិនកោងដាក់គេវិញ,

៤- នអហោសិ មិនប្លន់គេយក ។

## បំណង ៣ យ៉ាងគឺៈ

១- បុត្តគីវេ កូនជាចំណង ក,

២- ភរិយាហត្ថេ ប្រពន្ធជាចំណងដៃ,

៣- ធនំបាទេ ទ្រព្យជាចំណងជើង ។

## វត្ថុបរិភោគមិនឆ្អែត ៣ យ៉ាងគឺ

១- និទ្ទាយតិ ការដេកក៏មិនចេះឆ្អែត,

២- សុរាមេរយៈ ការសេពសុរានិងមេរ័យ ក៏មិនចេះឆ្អែត,

៣- មេថុនំ ការសេពនូវមេថុនធម្មក៏មិនចេះឆ្អែត ។

## ស្រវឹង ៣ យ៉ាង

១- យោព្វនមទោ ស្រវឹងវ័យ,

២- អរោគមនោ ស្រវឹងក្នុងខ្លួនថា ជាអ្នកគ្មានរោគ,

៣- ជាតិមនោ ស្រវឹងក្នុងជាតិមានយសសក្តិខ្ពង់ខ្ពស់ជាដើម

## អបេសនៈធម៌ ៣ យ៉ាង

១- ភាវេតិ ប្រែថា ចំរើន,

២- វិនោទេតិ ប្រែថា បន្ទោរបង់,

៣- បជហាតិ ប្រែថា លះបង់,

## ភាវេតិ បែកចេញជា៣យ៉ាង

១- ទាន, ២- សីល, ៣- ភាវនា ។

## វិនោទេតិ បែកចេញជា ៣ យ៉ាង

១- កាមវិតក្កោ បន្ទោរបង់នូវសេចក្តីត្រិះរិះក្នុងកាម,

២- ព្យាបាទវិតក្កោ បន្ទោរបង់នូវការត្រិះរិះក្នុងការព្យាបាទ,

៣- អវិហឹសាវិតក្កោ បន្ទោរបង់នូវការត្រិះរិះដើម្បីបៀតបៀន ។

## បជហតិ បែកចេញជា ៣ យ៉ាង

១- រាគៈ ២- លោភៈ ៣- ទោសៈ ។

## លក្ខណមនុស្សឧស្សាហ៍ ៣ យ៉ាង

១- អនិក្ខិត្តធុរតា ប្រញាប់ធ្វើធុរៈ ដែលកាត់ទុកមិនចោលធុរៈ,

២- អនិព្វិន្នតា ធ្វើការងារដែលមកដល់ដៃមិនបង្អង់យូរ,

៣- អសង្ករតា ធ្វើការងារតាមវេលាមិនបង្អង់ថ្ងៃ ។

## លក្ខណៈមនុស្សខ្ជិល ៣ យ៉ាង

១- និក្ខិត្តធុរតា ជាមនុស្សចោលធុរៈ ដែលកាត់ទុករបស់ នឹងធ្វើ

២- និព្វិន្នតា នឿយណាយដល់ការងារចំពោះមុខ,

៣- សតិសង្ករតា បង្អែរបង្អង់វេលារឿយៗ ទៅ ។

## ផលមនុស្សខ្ជិលដោយលំដាប់ ៦ យ៉ាង (៩)

១- អលសស្ស កុតោសិប្បំ មនុស្សខ្ជិលមិនជួបប្រទះវិជ្ជា,

២- អសិប្បស្ស កុតោធនំ គ្មានវិជ្ជានឹងរកទ្រព្យបានមកពីណា,

៣- អធនស្ស កុតោមិត្តំ គ្មានទ្រព្យអ្នកណានឹងចងជាមិត្ត,

៤- អមិត្តស្ស កុតោសុខំ គ្មានមិត្តនឹងរកសេចក្ដីសុខមកពីណាបាន,

៥- អសុខស្ស កុតោបុញ្ញំ គ្មានសេចក្ដីសុខ នឹងរកបុណ្យមកពីណាបាន,

៦- អបុញ្ញស្សក្រុកោធិញានំ គ្មានបុណ្យនឹងបណ្តុះព្រះនិព្វាន មកពីណាមក ។

## ធម៌ ៣ សម្លាប់ធម៌ ៣

១- សម្លាប់លោភៈ ដោយសមាធិខន្ធ,

២- សម្លាប់ទោសៈ ដោយសីលខន្ធ,

៣- សម្លាប់មោហៈ ដោយកងបញ្ញា,

រមែងយាត្រាទៅកាន់និព្វាន ។

## បតុក្កៈ ពួក ៤

## វុឌ្ឍិ «ធម៌ជាគ្រឿងបំរើន» ៤ យ៉ាង

១- សប្បុរិសូបសំសេវ សេពគប់សប្បុរស គឺលោកអ្នកប្រព្រឹត្តិល្អដោយកាយ វាចា ចិត្ត,

២- សទ្ធម្មស្សវនៈ ស្តាប់ពាក្យប្រដៅរបស់លោកដោយគោរព,

៣- យោនិសោមនសិការៈ ត្រិះរិះឱ្យស្គាល់របស់ល្អ ឬ អាក្រក់ដោយឧបាយដែលត្រូវ,

៤- ធម្មានុធម្មប្បដិបត្តិ ប្រតិបត្តធម៌ សមគួរដល់ធម៌ដែលបានត្រិះរិះឃើញហើយ ។

## បក្កៈ ៤ យ៉ាង

១- បដិរូបទេសវាសៈ នៅក្នុងប្រទេសដ៏សមគួរ,

២- សប្បុរិសូបសំសេវ សេពគប់សប្បុរស,

៣- អត្តសម្មាបណិធិ តាំងខ្លួនដោយប្រពៃ,

៤- បុព្វេកតបុញ្ញតា ភាពជាអ្នកបានធ្វើបុណ្យទុកពីក្នុងកាលមុន ។

## អគតិ ៤ យ៉ាង

១- ឆន្ទាគតិ លំអៀងព្រោះស្រលាញ់,

២- ទោសាគតិ　　　លំអៀងព្រោះស្អប់,

៣- មោហាគតិ　　　លំអៀងព្រោះល្ងង់,

៤- ភយាគតិ　　　លំអៀងព្រោះខ្លាច ។

## អន្តរាយរបស់ភិក្ខុ-សាមណេរបួសថ្មី ៤ យ៉ាង

១- មិនអត់ធន់ដល់ពាក្យទូន្មាន ខ្ជិលធ្វើតាម,

២- ជាមនុស្សឃើញតែការបរិភោគជាប្រមាណ មិនអត់ធន់ដល់សេចក្ដីស្រេកឃ្លាន,

៣- ត្រេកអរក្នុងកាមគុណចង់បានតែសេចក្ដីសុខលើសលប់ឡើងទៅ,

៤- ស្រលាញ់ស្ត្រីភាព ។

ភិក្ខុ-សាមណេរប្រាថ្នាសេចក្ដីចំរើនដល់ខ្លួន គួរប្រយ័ត្នកុំឱ្យអន្តរាយ ៤យ៉ាងនេះមកញាំញីបាន ។

## បធាន « ព្យាយាម » ៤ យ៉ាង

១- សំវរប្បធាន: ព្យាយាមប្រយ័ត្នមិនឱ្យបាបកើតឡើងក្នុងសន្ដាន,

២- **បហានប្បធាន:**　　ព្យាយាមលះបាបដែលកើតឡើង,

៣- ភាវនាបធាន:　　ព្យាយាមញ៉ាំងកុសលឱ្យកើតឡើងក្នុងសន្ដាន,

៤- អនុរក្ខនាបធាន ព្យាយាមរក្សាកុសលដែលកើតឡើងហើយមិនឱ្យ

សាបសូន្យទៅវិញ ។

ព្យាយាម ៤ យ៉ាងនេះជាធម៌ប្រពៃ គួរប្រកបឱ្យកើតមានក្នុងសន្តាន ។

## អធិដ្ឋានធម៌ «ធម៌ដែលគួរតាំងទុកក្នុងចិត្ត» ៤ យ៉ាង

១- បញ្ញា ដឹងរបស់ដែលគួរដឹង,

២- សច្ចៈ សេចក្តីពិតក្នុងចិត្ត គឺតាំងចិត្តនិងធ្វើអ្វីក៏ធ្វើពិត,

៣- ចាគៈ លះរបស់ដែលជាសត្រូវដល់សេចក្តីពិតក្នុងចិត្ត,

៤- ឧបសមៈ ស្ងប់ចិត្តចាករបស់ដែលជាសត្រូវ ចំពោះសេចក្តីស្ងប់ ។

## ឥទ្ធិបាទ គុណធម៌ជាគ្រឿង ឱ្យសម្រេចប្រយោជន៍ ៤ យ៉ាង

១- ឆន្ទៈ ចូលចិត្តស្រលាញ់ក្នុងកិច្ចការនោះៗ,

២- វិរិយៈ ព្យាយាមប្រកបកិច្ចការនោះៗ,

៣- ចិត្តៈ យកចិត្តទុកដាក់ក្នុងកិច្ចការនោះៗមិនដាក់ធុរៈ,

៤- វិមំសា ឧស្សាហ៍ត្រិះរិះពិចារណារកហេតុផលក្នុងកិច្ចការនោះៗ ។

## គួរធ្វើសេចក្ដីមិនប្រមាទក្នុងទី ៤ ស្ថាន

១- កាយទុច្ចរិតប្បហានៈ ក្នុងការលះកាយទុច្ចរិត ប្រព្រឹត្តកាយសុចរិត,

២- វចីទុច្ចរិតប្បហានៈ ក្នុងការលះវចីទុច្ចរិតប្រព្រឹត្តវចីសុច្ចរិត

៣- មនោទុច្ចរិតប្បហានៈ ក្នុងការលះមនោទុច្ចរិត ប្រព្រឹត្តមនោ-សុចរិត,

៤- មិច្ឆាទិដ្ឋិប្បហានៈ ក្នុងការលះសេចក្ដីឃើញខុស ធ្វើសេចក្ដីឃើញឱ្យត្រូវ ។

## មួយទៀតគួរប្រយ័ត្នបិត្តកុំឱ្យវង្វេងក្នុងទី ៤ ស្ថាន

១- រជនីយៈ កុំត្រេកអរក្នុងអារម្មណ៍ដែលនាំឱ្យមានតម្រេក,

២- ទោសនីយៈ កុំខឹងក្នុងអារម្មណ៍ដែលនាំឱ្យខឹង,

៣- មោហនីយៈ កុំវង្វេងក្នុងអារម្មណ៍ដែលនាំឱ្យវង្វេង,

៤- មទនីយៈ កុំស្រវឹងក្នុងអារម្មណ៍ដែលនាំឱ្យស្រវឹង ។

## អារក្ខកម្មដ្ឋាន «កម្មដ្ឋានដែលគួរបំរើនជានិច្ច» ៤ យ៉ាង

១- ពុទ្ធានុស្សតិ រឭកដល់គុណព្រះពុទ្ធដែលមានក្នុងព្រះអង្គ នឹងគុណដែលទ្រង់សង្គ្រោះដល់អ្នកដទៃ,

២- មេត្តា ផ្សាយមេត្តាចិត្តគិតឱ្យមនុស្សសត្វទាំងពួងបានសេច-
ក្តីសុខគ្រប់គ្នា,

៣- អសុភៈ ពិចារណាពង្កកាយខ្លួន និងអ្នកដទៃឱ្យឃើញថាជារបស់បដិកូលគួរខ្ពើម,

៤- មរណស្សតិ នឹកដល់សេចក្តីស្លាប់ដែលនឹងមានដល់ខ្លួន ។

## ព្រហ្មវិហារ ៤ យ៉ាង

១- មេត្តា សេចក្តីស្រលាញ់ប្រាថ្នាឱ្យគេបានសុខ,

២- ករុណា សេចក្តីអាណិតគិតជួយឱ្យគេរួចចាកទុក្ខ,

៣- មុទិតា សេចក្តីត្រេកអរតាមក្នុងវេលាដែលគេបានល្អ,

៤- ឧបេក្ខា សេចក្តីតាំងចិត្តជាកណ្តាល មិនឱ្យសោមនស្ស ទោមនស្សក្នុងវេលាដែលគេមានសេចក្តីវិបត្តិ ។

ធម៌ ៤ យ៉ាងនេះជាគ្រឿងប្រព្រឹត្តរបស់អ្នកធំ ។

## សតិប្បដ្ឋាន ៤ យ៉ាង

១- កាយានុបស្សនា សតិរឭកពិចារណាកាយជាអារម្មណ៍ថា កាយនេះគ្រាន់តែជាកាយប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

២- វេទនានុបស្សនា សតិរឭកពិចារណាវេទនា គឺសេចក្តីសុខទុក្ខ ឧបេក្ខាជាអារម្មណ៍ថា វេទនានេះគ្រាន់តែជាវេទនាប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

៣- ចិត្តានុបស្សនា សតិរឭកពិចារណាចិត្តដែលសៅហ្មងនិងផូរផង់ជាអារម្មណ៍ថាចិត្តនេះគ្រាន់តែជាចិត្តប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

៤- ធម្មានុបស្សនា សតិរឭកពិចារណា ធម៌ជាកុសល ឬអកុសលដែលកើតឡើងជាមួយនិងចិត្តជាអារម្មណ៍ថា ធម៌នេះគ្រាន់តែជាធម៌ប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

## ធាតុកម្មដ្ឋាន ៤ យ៉ាង

ធាតុ ៤ គឺ ៖ ១-បឋវីធាតុ ធាតុដី, ២ អាបោធាតុ ធាតុទឹក, ៣- តេជោធាតុ ធាតុភ្លើង, វាយោធាតុ ធាតុខ្យល់ ។ ធាតុណាមានលក្ខណៈរឹងធាតុនោះឈ្មោះថា បឋវីធាតុ ៗ នោះដែលជាខាងក្នុងមាន ១៩ គឺ៖ កេសា សក់, លោមា រោម, នខា ក្រចក, ទន្តា ធ្មេញ, តចោ ស្បែក, មំសំ សាច់, នហារូ សរសៃ, អដ្ឋិ ឆ្អឹង, អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង, វក្កំ តម្រងបស្សាវៈ, ហទយំ បេះដូង, យកនំ

ថ្លើម, កិលោមកំ វាវ, បិហកំ ក្រពះ, បប្ផាសំ សួត, អន្តំ ពោះវៀនធំ, អន្តគុណំ ពោះវៀនតូច, ឧទរិយំ អាហារថ្មី, ករីសំ អាហារចាស់ ។

ធាតុណាមានលក្ខណៈរាវជ្រួតជ្រាប ធាតុនោះឈ្មោះថា អាបោធាតុៗនោះដែលជាខាងក្នុងមាន ១២ គឺៈ

បិត្តំ ប្រមាត់, សេម្ហំ ស្លេស, បុព្វោ ខ្ទុះ, លោហិតំ ឈាម, សេទោ ញើស, មេទោ ខ្លាញ់ខាប់, អស្សុ ទឹកភ្នែក, វសា ខ្លាញ់រាវ, ខេឡោ ទឹកមាត់, សិង្ឃានិកា ទឹកសម្បោ, លសិកា ទឹករំអិល, មុត្តំ ទឹហមូត្រ ។

ធាតុណាមានលក្ខណៈក្តៅ ធាតុនោះឈ្មោះថាតេជោធាតុៗនោះដែលជាខាងក្នុងមាន ៤ គឺៈ ១ សន្តប្បត្តិ ភ្លើងដែលញាំងកាយឱ្យក្តៅ, ២- ជិរណាគ្គិ ភ្លើងដែលញាំងកាយឱ្យទ្រុឌទ្រោម, ៣- បរិណាមគ្គិ ភ្លើងដែលញាំងកាយឱ្យក្រហល់ក្រហាយ, ៤- បរិទយ្ហគ្គិ ភ្លើងដែលដុតអា-អាហារឱ្យរលួយ ។

ធាតុណាមានលក្ខណៈបក់ទៅមក ធាតុនោះឈ្មោះថា វាយោធាតុៗនោះដែលជាខាងក្នុងមាន ៦ គឺៈ

១- ឧទ្ធង្គមវាត ខ្យល់បក់ឡើងលើ, ២ អធោគមវាត ខ្យល់បក់ចុះក្រោម, ៣ កុច្ឆិសយវាត ខ្យល់បក់ក្នុងពោះ, ៤ កោដ្ឋាសយវាត ខ្យល់បក់ក្នុងពោះវៀន, ៥ អង្គមង្គានុសារិវាត ខ្យល់បក់តាមរាង

កាយ, ៦- អស្សាសប្បស្សាសវាត ខ្យល់ដកដង្ហើមចេញចូល ។

សេចក្តីកំណត់ពិចារណាកាយនេះឱ្យឃើញថា គ្រាន់តែជាធាតុ ៤ គឺ ដី, ទឹក, ភ្លើង, ខ្យល់, ប្រជុំគ្នាប៉ុណ្ណោះ មិនមែនយើង មិនមែនរបស់យើងដូច្នេះ ហៅថាធាតុកម្មដ្ឋាន ។

## អរិយសច្ច ៤ យ៉ាង

១- ទុក្ខ, ២- សមុទយ, ៣- និរោធ, ៤- មគ្គ

សេចក្តីមិនសប្បាយកាយ - សប្បាយចិត្ត - ឈ្មោះថាទុក្ខព្រោះជារបស់ដែលសត្វអត់ធន់បានដោយកម្រ ។

តណ្ហា គឺសេចក្តីអន្ទះអន្ទែងចង់បាន ឈ្មោះថាសមុទ័យៈព្រោះជាហេតុឱ្យកើតទុក្ខ ។ តណ្ហានោះ មាន ៣ប្រភេទ គឺ តណ្ហាក្នុងអារម្មណ៍ដែលជាទីស្រលាញ់ពេញចិត្ត ហៅថា កាមតណ្ហា១, តណ្ហាក្នុងសេចក្តីចង់បានជានេះជានោះ ហៅថា ភវតណ្ហា១, តណ្ហាក្នុងសេចក្តីមិនចង់បានជានេះជានោះ ហៅថា វិភវតណ្ហា១ ។

សេចក្តីរលត់តណ្ហាបាន ទុក្ខរមែងរលត់អស់ ឈ្មោះថា និរោធ ព្រោះជាសេចក្តីរលត់ទុក្ខ ។

បញ្ញាដែលឃើញប្រពៃថានេះជាតួទុក្ខ នេះជាតួហេតុឱ្យកើតទុក្ខ នេះជាសេចក្តីរលត់ទុក្ខ នេះជាផ្លូវនាំឱ្យរលត់ទុក្ខ ឈ្មោះថាមគ្គ ក្រោជាផ្លូវប្រតិបត្តិឱ្យដល់នូវសេចក្តីរលត់ទុក្ខ ។

# ពុទ្ធភាសិត

# អំពីបញ្ញា

## បញ្ញាកើតឡើងដោយហេតុ ៣ យ៉ាង

១- ចិន្តាមយបញ្ញា បញ្ញាកើតឡើងអំពីការគិត,

២- សុតាមយបញ្ញា បញ្ញាកើតឡើងអំពីកាស្តាប់ឬរៀន,

៣- ភាវនាមយបញ្ញា បញ្ញាកើតឡើងអំពីការចំរើនមេត្តាភាវនា ។

## ហេតុឱ្យកើតបញ្ញា ៨ យ៉ាង

១- អាចារគារវោ, ២-បរិបុច្ឆកតា, ៣- បាបវិរតិ, ៤- សីលសំវរោ, ៥- ពាហុសច្ចៈ, ៦- សតិ, ៧- វិរិយារម្ភ, ៨-បញ្ញា ។

## សមុដ្ឋាននឹងកើតបញ្ញាមាន ៨ យ៉ាង

១- ជាមនុស្សមានវ័យល្អ, ២- បានយសបរិវារ,

៣- មិនសេពគប់ស្ត្រី, ៤- ខំសាកសួរ,

៥- មានកិច្ចជាឧបាយ, ៦- និយាយតែអត្ថនិងធម៌,

៧- មានចិត្តស្នេហាក្នុងធម៌, ៨- នៅក្នុងប្រទេសដ៏សមគួរ ។

## មូលរបស់បញ្ញាមាន ២ យ៉ាង

១- សីលវិសុទ្ធិ បានដល់សីល ៤,

២- ចិត្តវិសុទ្ធិ បានដល់ចិត្តជាកុសល ។

## លក្ខណៈបញ្ញា ៣ យ៉ាង

១- ដឹងច្បាស់នូវចិត្តនិងចេតសិក ដែលមិនច្រឡំគ្នា,

២- ដឹងច្បាស់នូវឧបាយ,

៣- ដឹងនូវកិរិយានៃអកុសល ។

## ខ្លឹមរបស់បញ្ញាមាន ៣ យ៉ាង

១- អនិច្ចំ, ២- ទុក្ខំ, ៣- អនត្តា ។

## ភូមិរបស់បញ្ញាមាន ៦ យ៉ាង

១- ខន្ធ, ២- អាយតនៈ, ៣- ធាតុ, ៤- ឥន្ទ្រីយ៍,

៥- សច្ចៈ ទាំង ៤ , ៦- បដិច្ចសមុប្បាទ ។

## អានិសង្សរបស់បញ្ញាមាន ៤ យ៉ាង

១- កំចាត់បង់នូវកិលេស,

២- សោយរសអរិយផលទាំង ៤,

៣- អាចចូលនិរោធសម្មាបត្តិ,

៤- អាចលើកខ្លួនឱ្យឡើងដល់ថ្នាក់ ។

## បញ្ញាបែកជា ២ យ៉ាង

១- លោកិយប្បញ្ញា        បញ្ញាលោកជាបុថុជ្ជន,

២- លោកុត្តរប្បញ្ញា        បញ្ញាលោកុត្តរៈ ។

## ផលស្ដាប់ធម៌មាន ៤ យ៉ាង គឺ

១- ពុទ្ធសាសនំ វិរោចេតិ  នឹងញុំាងព្រះពុទ្ធសាសនាឱ្យរុងរឿង,

២- ពហុសុតោ        នឹងបានចេះដឹងនូវពុទ្ធវចនច្រើន,

៣- សុគតិបរាយនោ        លុះស្លាប់ទៅនឹងបានសុគតិទៅខាងមុខ

៤- បដិវេធ        នឹងបានត្រាស់ដឹងនូវមគ្គនិងផល ។

## ឧបនិស្ស័យការស្ដាប់ធម៌ ៤ យ៉ាង (៩)

១- សោតំបាវតិ        ជាប្រឡាយទៅកាន់សោតា,

២- ឧគ្គណ្ហន្តិ        រៀនយកនូវព្រះសូត្រ, ព្រះវិន័យ, ព្រះអភិធម្ម,

៣- វាចនំ        ប្រាប់ធម៌សម្ដែងធម៌ដល់អ្នកដទៃ,

៤- សជ្ឈាយំ        ស្វាតធ្យាយទន្ទេញ ។

## អានិសង្សកតញ្ញូ ៤ យ៉ាងគឺ

១- កុសលមូលតា        ជាឫសគល់នៃកុសលទាំងពួង,

២- បធានតា        ជាប្រធាននៃបារមីទាំង៣០,

៣- បុញ្ញាភិវឌ្ឍនោ        ជាទីចំរើនបុណ្យកុសល,

៤- សម្បត្តិសមិច្ឆនា ជាទីសម្រេចនូវសម្បត្តិទាំង ៣ ស្ថាន គឺៈ សម្បត្តិមនុស្ស ទេព្តា-ព្រះនិព្វាន ។

## ស្តាប់ធម៌មិនបានផលប្រយោជន៍ ៥ យ៉ាងគឺ

១- មក្ខីធម្មំសុណាតិ ស្តាប់ធម៌ដោយមើលងាយគេ,

២- អារម្ភចិត្តោធម្មំសុណាតិ ស្តាប់ធម៌ដោយរករឿងលើកទោស,

៣- ទុប្បញ្ញាមុឡ្ហោហោតិ ស្តាប់ធម៌គ្មានធម៌គ្មានបញ្ញា ស្តាប់លូង់ខ្លៅ,

៤- អសញ្ញាតេ អសញ្ញាតមានីហោតិ ប្រកាន់ថាអញដឹងហើយត្រង់ហ្នឹង,

៥- ធម្មទេសនេ អហតបត្តោហោតិ ស្តាប់ធម៌មានចិត្តប្រទុស្តអ្នកសម្តែងវិញ ។

## ទោសស្តាប់ធម៌ ៧ យ៉ាង

១- បាទានំបសារេត្វា សណ្តូកជើងស្តាប់ធម៌ ស្លាប់ទៅ ទៅកើតជាមនុស្សខ្វិន,

២- វាចនំពធិរោហោតិ ស្តាប់ធម៌និយាយគ្នា ស្លាប់ទៅ ទៅកើតជាមនុស្សថ្លង់,

៣- និន្ទិត្វា មនុក្ខោហោតិ ស្តាប់ធម៌និន្ទាគេ និយាយដើមគេ ស្លាប់ទៅៗ កើតជាមនុស្សស្អុយមាត់,

៤- និប្បន្នា អដ្ឋវត្ថុពោហោតិ ស្ដាប់ធម៌ដេកស្ដាប់ ទៅកើតជាពស់ថ្លាន់,

៥- ចិន្តអញ្ញំ មគដំហោតិ ស្ដាប់ធម៌គិតអ្វីផ្សេងៗ ស្ដាប់ទៅៗ កើតជាសត្វស្វាប,

៦- អញ្ញំ កុញ្ជន្តិ ទុគន្ធោហោតិ ស្ដាប់ធម៌បរិភោគអាហារ ស្ដាប់ទៅកើតជាមនុស្សខ្ទិនស្អុយ,

៧- អញ្ញំ លិក្ខិតំ មហឹសោហោតិ ស្ដាប់ធម៌គូរវាសអ្វីលេងផ្សេងៗ ស្ដាប់ទៅៗ កើតជាក្របី,

(ទោសស្ដាប់ធម៌ ៧ យ៉ាងនេះ សូមព្រះករុណាគ្រប់ព្រះអង្គ អស់លោកអ្នកអានជាទីមេត្រី, មុននឹងជឿ សូមប្រើបញ្ញាបន្តិច ព្រោះផ្លូវព្រះសូត្រ) ។

## អានិសង្សខន្តី ៥ យ៉ាង

១- បិយោមនាបោ នឹងបានជាទីស្រលាញ់រាប់អានរបស់ទេវតានិងមនុស្សទាំងឡាយ,

២- នវេរពហុលោ នឹងមិនចំរើនទៅដោយពៀរវេរា,

៣- នវជ្ជពហុលោ នឹងមិនបានចំរើនទៅដោយទោស,

៤- អសម្មុឡ្ហោ នឹងមានស្មារតីមិនវង្វេងក្នុងវេលាស្លាប់,

៥- សុគតិ ស្លាប់ហើយនឹងបានទៅកើតក្នុងស្ថានសួគ៌ ។

## អំពីទ្វីបមាន ៤ យ៉ាង គឺ

១- បូរីនិទ្វីប, ទ្វីប ខាងកើត, មានដើមច្រេសជាប្រចាំទ្វីប,

២- អាម៉គោយានីទ្វីប, ទ្វីបខាងត្បូង, មានដើមខ្នុំ,

៣- ឧត្តរកពោទ្វីប, ទ្វីប ខាងជើង, មានដើមកាល្បព្រឹក្ស,

៤- ជម្ពូទ្វីប, ទ្វីប យើងនេះ មានដើមព្រីង ។

### ដំណឹងសៀវភៅចេញថ្មី

សៀវភៅជីវិតគ្រប់លក្ខណ៍ ស្តីអំពីចរិយាសាស្ត្រ រៀបរៀងដោយភិក្ខុធម្មបាលោ ទៀវ-ជុំ នឹងមានចេញលក់ក្នុងពេលឆាប់ ៗ នេះ ។

## បញ្ចកៈ ពួក ៥

## អនន្តរិយកម្ម ៥ យ៉ាង

១- មាតុឃាត សម្លាប់មាតា,

២- បិតុឃាត សម្លាប់បិតា,

៣- អរហន្តឃាត សម្លាប់ព្រះអរហន្ត,

៤- លោហិតុប្បាទ ប្រទុស្តព្រះពុទ្ធអង្គរហូតដល់ញុំាងលោហិតឱ្យពុរពង ឬ ឱ្យជាំជាំ,

៥- សង្ឃភេទ ញុំាងសង្ឃឱ្យបែកគ្នា ។

កម្ម ៥ យ៉ាងនេះ ជាបាបធ្ងន់ ឃាត់សួគ៌ ឃាត់និព្វាន តាំងនៅក្នុងឋានបរាជិករបស់អ្នកកាន់ព្រះពុទ្ធសាសនាហាមមិនឱ្យធ្វើយ៉ាងដាច់ខាត ។

## អភិណ្ហប្បច្ចវេក្ខណៈ ៥ យ៉ាង

គ្រហស្ថបព្វជិត គួរពិចារណាធម៌ ៥ ប្រការនេះរាល់ថ្ងៃ ថាៈ

១- ជរាធម្មោម្ហិ អាត្មាអញមានសេចក្តីឈឺចាស់ជរាធម្មតាមិនកន្លងសេចក្តីចាស់ជរាបានឡើយ,

២- ព្យាធិធម្មោម្ហិ អាត្មាអញមានសេចក្តីឈឺចាប់ជាធម្មតាមិនកន្លងសេចក្តីឈឺចាប់បានឡើយ,

៣- មរណធម្មោម្ហិ អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់បានឡើយ,

៤- សព្វេហិ មេ បិយេហិ អាត្មាអញមានសេចក្តីព្រាត់ប្រាសចាករបស់ជាទីស្រលាញ់ជាទីគាប់ចិត្តទាំងអស់,

៥- កម្មស្សកោម្ហិ អាត្មាអញមានកម្មជារបស់ខ្លួន, អាត្មាអញធ្វើកម្មល្អ នឹងបានផលល្អ ធ្វើកម្មអាក្រក់នឹងបានផលអាក្រក់ ។

## វេសារជ្ជករណធម៌ ធម៌ធ្វើឱ្យក្លាហាន ៥ យ៉ាង

១- សទ្ធា ជឿរបស់ដែលគួរជឿ,

២- សីល រក្សាកាយវាចាឱ្យរៀបរយ,

៣- ពាហុសច្ចៈ ភាពជាអ្នកសិក្សារៀនសូត្រច្រើន,

៤- វិរិយារម្ភៈ ប្រារព្ធសេចក្តីព្យាយាម,

៥- បញ្ញា ដឹងរបស់ដែលគួរដឹង ។

## អង្គនៃភិក្ខុបួសថ្មី ៥ យ៉ាង

១- សង្រួមក្នុងព្រះបាដិមោក្ខ គឺវៀរចាកទោសដែលទ្រង់ហាម ធ្វើតាមខដែលទ្រង់អនុញ្ញាត,

២- សង្រួមឥន្ទ្រីយ៍ គឺប្រយ័ត្នភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ,

ចិត្ត, មិនឱ្យសោមនស្ស ទោមនស្សគ្របសង្កត់ចិត្ត, ក្នុងវេលាដែលបានឃើញរូបជាដើម,

៣- ជាអ្នកមិននិយាយសប្បាយហេហា,

៤- នៅក្នុងសេនាសនៈស្ងាត់,

៥- មានសេចក្ដីឃើញត្រូវ ។

ភិក្ខុបួសថ្មីត្រូវតាំងនៅក្នុងធម៌ ៥ យ៉ាងនេះឱ្យខ្ជាប់ខ្ជួន ។

## អង្គនៃធម្មកថិក អ្នកសម្ដែងធម៌ ៤ យ៉ាង

១- សម្ដែងធម៌តាមលំដាប់ មិនច្រូតកាត់ពេកឱ្យខូចសេចក្ដី,

២- លើកយកហេតុផលមកអាង ណែនាំឱ្យអ្នកស្ដាប់ចូលចិត្ត,

៣- តាំងចិត្តមេត្តាប្រាថ្នាឱ្យជាប្រយោជន៍ដល់អ្នកស្ដាប់,

៤- មិនសម្ដែងធម៌លើកខ្លួនឯង បន្ទុះបង្អាប់អ្នកដទៃ ។

ភិក្ខុជាធម្មកថិក គប្បីតាំងអង្គទាំង ៥ យ៉ាងនេះទុកក្នុងខ្លួន ។

## ធម្មស្សវនានិសង្ស អានិសង្សនៃការស្ដាប់ធម៌ ៥ យ៉ាង

១-អសុតំ សុណាតិ រមែងបានស្ដាប់ធម៌ដែលមិនទាន់បានស្ដាប់,

២- សុតំ បរិយោទបេតិ ធម៌ណាដែលធ្លាប់បានស្ដាប់ហើយតែមិន

ទាន់ចូលចិត្តនឹងចូលចិត្តច្បាស់ឡើង,

៣- កង្ខំ វិហនតិ រមែងកំចាត់បង់នូវសេចក្តីសង្ស័យចេញបាន,

៤- ទិដ្ឋឹ ឧជុំ ករោតិ រមែងធ្វើសេចក្តីឃើញឱ្យត្រង់តាមការពិត,

៥- ចិត្តមស្ស បសីទតិ ចិត្តអ្នកស្តាប់នោះ រមែងជ្រះថ្លា ។

## ពលៈ ធម៌ជាកម្លាំង ៥ យ៉ាង

១- សទ្ធា សេចក្តីជឿ,

២- វិរិយៈ សេចក្តីព្យាយាម,

៣- សតិ សេចក្តីរឭកបាន,

៤- សមាធិ សេចក្តីតាំងចិត្តខ្ជាប់,

៥- បញ្ញា សេចក្តីដឹងស្គាល់ការណ៍ខុសត្រូវ,

ធម៌ ៥ យ៉ាងនេះហៅថា ‹‹ឥន្ទ្រិយ›› ក៏បាន ព្រោះជាធំក្នុងកិច្ចរបស់ខ្លួន ។

## នីវរណៈធម៌ ៥ យ៉ាង

ធម៌ដែលជាគ្រឿងរាំងរាហាមចិត្ត មិនឱ្យបានសម្រេចសេចក្តីល្អហៅថា នីវរណៈមាន ៥ យ៉ាង:

១- កាមច្ឆន្ទៈ ស្រលាញ់ចូលចិត្តក្នុងអារមណ៍មានរូបជាដើមដែល

ជាទីគាប់ចិត្ត,

២- ព្យាបាទ: ចង់ចិត្តគំនុំគំគួនអ្នកដទៃ,

៣- ថីនមិទ្ធ: ដំណើរដែលចិត្តរួញថយនិងដំណើរងងុយងោកងក់,

៤- ឧទ្ធច្ច កុក្កុច្ច: ដំណើរដែលចិត្តរាយមាយ និងរសាប់រសល់,

៥- វិចិកិច្ឆា សេចក្ដីសង្ស័យមិនចេះដាច់ស្រេច ។

## ខន្ធ ៥

កាយនិងចិត្តនេះ ចែកចេញជា៥កង ហៅថា ខន្ធ៥ គឺ រូប, វេទ-នា, សញ្ញា, សង្ខារ, វិញ្ញាណ ។

# ពួកកាយវង្ស

# អំពីសាសនា

## ហេតុដែលនាំឱ្យកើតសាសនាមាន ៣ យ៉ាង

១- *សេចក្ដីខ្លាច*

២- *សេចក្ដីត្រូវការ*

៣- *សេចក្ដីខ្វះខាត*

## សាសនាមាន ២ យ៉ាង

១- *ពុទ្ធសាសនា,*

២- *ពាហិរសាសនា ។*

*ពុទ្ធសាសនា, ប្រែថា ពាក្យប្រៀនប្រដៅ ពាក្យឱវាទ, ឬដំបូន្មានរបស់ព្រះពុទ្ធ ។*

*ពាហិរសាសនា គឺពាក្យប្រៀនប្រដៅរបស់គណាចារ្យដទៃ គឺសាសនាបន់ស្រន់បួងសួង ឬសាសនាអង្វរករ បានដល់សាសនាព្រាហ្មណ៍ជាដើម សាសនានេះជឿព្រះអាទិទេពឬព្រះឥសូរ ព្រះនរាយណ៍និងព្រះព្រហ្មថាជាសរណៈរបស់ខ្លួន ពាហិរសាសនានេះកើតមុនព្រះពុទ្ធសាសនាខ្លះក្រោយព្រះពុទ្ធសាសនាខ្លះ គឺកើតពីត្រឹមមានសត្វលោកមក ។*

# អំពីពាហិរសាសនា

គណាចារ្យដទៃដែលជាអ្នកប្រកាសពាហិរសាសនានោះ មានឥសី ១០ នាក់ គឺឈ្មោះអដ្ឋកៈ១, វាមកៈ១, វាមទេវៈ១, វេស្សាមិត្តៈ១, យមតគ្គិ១, អង្គីរសៈ១, ភារទ្វាជៈ១, វាសេដ្ឋៈ១, កស្សបៈ១, ភគុ១, ជាអ្នកប្រកាសតៗ គ្នានូវលទ្ធិព្រហ្មញ្ញៈ ឬព្រាហ្មណ្យ នាំមនុស្សឱ្យជឿថាមហាព្រហ្មជាអ្នកបង្កើតពពួកសត្វ ពាក្យប្រៀនប្រដៅរបស់ឥសីទាំងនេះហៅថាព្រហ្មញ្ញសាសនា ។ គ្រូទាំង៦ឈ្មោះបូរណកស្សប១, មក្ខលិគោសាល១ និគ្គណ្ឋនាថបុត្ត១, សញ្ជយវេឡដ្ឋបុត្ត១, បកុទូកច្ចាយនៈ១, អជិតកេសកម្ពលី ១, ជាអ្នកប្រកាសព្រមគ្នានូវលទ្ធិមិច្ឆាទិដ្ឋិមានអកិរិយាទិដ្ឋិជាដើមប្រកាសជឿថា ធ្វើបុណ្យមិនបានបុណ្យ ធ្វើបាបមិនបានបាបពាក្យប្រៀនប្រដៅរបស់គ្រូទាំងនេះឈ្មោះសាសនានិគ្រន្ថ ។

គ្រូឈ្មោះមហាម័ទ ជាអ្នកបង្កើតគម្ពីកោរ៉ានដឹកនាំមនុស្សឱ្យជឿតាមលទ្ធិរបស់ខ្លួនដែលសម្ដែងក្នុងគម្ពីរនោះ ពាក្យប្រៀនប្រដៅរបស់មហាម័ទនោះហៅថាសាសនាមហាម័ទ ។

មនុស្សអស្ចារ្យម្នាក់ឈ្មោះ ហ្ស៊េស៊ុយគ្រឹស្តប្រកាសលទ្ធិលាងបាបជាដើម ពាក្យប្រៀនប្រដៅរបស់លោកនេះ ហៅថាគ្រឹស្តសាសនាដែលបែកទៅជាកាតូលិក និងប្រូតិស្តង់ត៍ ។

ឯព្រះពុទ្ធសាសនាមិនដូច្នោះទេ គឺសេចក្តីណាមួយ ជាពុទ្ធដីការបស់ព្រះពុទ្ធនោះ បើសម្តែង អំពីហេតុសុទ្ធតែប្រាប់ផល បើសម្តែងអំពីផលសុទ្ធតែប្រាប់ហេតុ ។

## សាសនារុងរឿងដោយហេតុ ៥ យ៉ាង

១- សក្កច្ចំ ធម្មំ សុណន្តិ បរិស័ទទាំង ៤ ស្តាប់ធម៌ដោយគោរព ។

២- សក្កច្ចំ ធម្មំ បរិយាសុណន្តិ បរិស័ទទាំង៤រៀនធម៌ដោយគោរព។

៣- សក្កច្ចំ ធម្មំ ធារេន្តិ បរិស័ទទាំង៤ទ្រទ្រង់ធម៌ដោយគោរព ។

៤- សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ បរិស័ទទាំង៤ពិចារណា-នូវសេចក្តីនៃធម៌ដែលខ្លួនទ្រទ្រង់ ។

៥- សក្កច្ចំ ធម្មានំ អត្ថមញ្ញាយ បដិបជន្តិ បរិស័ទទាំង៤ដឹងសេចក្តី-អធិប្បាយនៃធម៌ហើយប្រតិបត្តិតាមធម៌ដោយគោរព ។

បរិស័ទទាំង៤នោះគឺ ភិក្ខុបរិស័ទ១, ភិក្ខុនីបរិស័ទ១, ឧបាសកបរិស័ទ១, ឧបាសិកាបរិស័ទ១ ។

## សាសនាសាបសូន្យទៅដោយហេតុ ៥ យ៉ាង

១- ន សក្កច្ចំ ធម្មំ សុណន្តិ បរិស័ទទាំង៤មិនស្តាប់ធម៌ដោយគោរព ។

២- ន សក្កច្ចំ ធម្មំ បរិយាសុណន្តិ បរិស័ទទាំង៤មិនស្តាប់ធម៌ដោយគោរព ។

៣- ន សក្កច្ចំ ធម្មំ ធារេន្តិ បរិស័ទទាំង៤មិនទ្រទ្រង់ធម៌ដោយគោរព

៤- ន សក្កច្ចំ ធាតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ បរិស័ទទាំង៤មិនពិចារណានូវសេចក្តីនៃធម៌ដែលខ្លួនទ្រទ្រង់ហើយ គឺមិនដឹងសេចក្តីអធិប្បាយនៃធម៌នោះដោយមិនយកចិត្តទុកដាក់ ។

៥- ន សក្កច្ចំ ធម្មានំ អត្ថមញ្ញាយ បដិបជន្តិ បរិស័ទទាំង៤មិនដឹងសេចក្តីនៃធម៌ ហើយមិនប្រតិបត្តិតាមដោយគោរព ។

## ខ្លឹមព្រះពុទ្ធសាសនាមាន ៥ យ៉ាង

១- សីលសារំ ខ្លឹមគឺសីល,

២- សមាធិសារំ ខ្លឹមគឺសមាធិ,

៣- បញ្ញាសារំ ខ្លឹមគឺបញ្ញា,

៤- វិមុត្តិសារំ ខ្លឹមគឺវិមុត្តិការរួចចាកកិលេស,

៥- វិមុត្តិញ្ញាណទស្សនសារំ ខ្លឹមគឺការឃើញថារួចចាកភព ។

## អំពីបង្អែកព្រះពុទ្ធសាសនាមាន ៣ យ៉ាង

ព្រះពុទ្ធ ១,

ព្រះធម៌ ១,

ព្រះសង្ឃ ១ ។

ត្រួយឬពន្លកនៃព្រះពុទ្ធសាសនាមានតែ ១

បានដល់ « ព្រះនិព្វាន » ។

ម្លប់ព្រះពុទ្ធសាសនាមាន ៣ យ៉ាង

១- សច្ចៈ,

២- ខន្តី,

៣- កតញ្ញូ.។

បន្ទល់ព្រះពុទ្ធសាសនាមានតែ១. គឺ.

បានដល់ « ព្រះវិន័យបិដក » ។

មែកព្រះពុទ្ធសាសនាមាន ៣ យ៉ាង គឺ

១- សីល,

២- សមាធិ,

៣- បញ្ញា ឬក៏បរិយត្តិធម៌ ៩, បដិបត្តិធម៌៩, បដិវេធធម៌

ឬក៏សុត្តន្តបិដក, ព្រះអភិធម្មបិដក ។

## អំពីជម្រៅព្រះពុទ្ធសាសនា ៤ យ៉ាង

១- ធម្មគម្ពីរ ជ្រៅដោយបាលី,

២- អត្ថគម្ពីរ ជ្រៅដោយសេចក្ដី,

៣- ទេសនាគម្ពីរ ជ្រៅដោយការសម្ដែង,

៤- បដិវេធគម្ពីរ ជ្រៅដោយការត្រាស់ដឹង ។

## វត្ថុតាងនៃព្រះពុទ្ធសាសនា

ពួកសត្វនិករបាននាំគ្នាប្រព្រឹត្តតាមព្រះទ្ធសាសនា សម្គាល់ឃើញវត្ថុជាភស្តុតាង មាន ៥ យ៉ាង ៖

១- ព្រះបដិមាករ រូបស្នងរបស់ព្រះពុទ្ធ,

២- ដើមពោធិព្រឹក្សជាឈើដែលព្រះតាស់ដឹង,

៣- ព្រះស្តូប ឬ ចេតិយ សម្រាប់បញ្ចុះព្រះធម្មក្ខន្ធ និងអដ្ឋិ របស់ព្រះសម្មាសម្ពុទ្ធ,

៤- ព្រះជិនធាតុ ធាតុរបស់ព្រះជិនស្រី,

៥- ព្រះធម្មក្ខន្ធ ៨៤០០០ ដែលតាំងនៅក្នុងភាជន៍ គឺបិដកទាំងបី ។

## អង្គរបស់សាមណេរមាន ៤ យ៉ាង

១- ខន្តី មានចិត្តអំណត់អត់ទ្រាំ,

២- អប្បមាទោ	មិនប្រហែសធ្វេសក្នុងកុសលធម៌,

៣- វត្ថិប្បហានំ	ត្រូវលះបង់ចោលនូវតម្រេកក្នុងកាម,

៤- អកិញ្ចនំ	មិនត្រូវខ្វល់ខ្វាយក្នុងការឥតប្រយោជន៍ ។

## អង្គរបស់ភិក្ខុមាន ៤ យ៉ាង គឺ

១- ពុទ្ធានុស្សតិ	រឭករឿយៗដល់ព្រះពុទ្ធ,

២- មេត្តា	ត្រូវផ្សាយមេត្តា,

៣- អសុភៈ	ត្រូវចម្រើនអសុភកម្មដ្ឋាន,

៤- មរណស្សតិ	រឭកដល់សេចក្តីស្លាប់ ។

## បព្វជ្ជាមាន ២ យ៉ាង

១- ពាហិរបព្វជ្ជា	បួសខាងក្រៅព្រះពុទ្ធសាសនា,

២- ធម្មវិនយបព្វជ្ជា	បួសក្នុងធម៌វិន័យព្រះពុទ្ធ ។

## បព្វជ្ជាមាន ៦ យ៉ាង

១- ឧបកីឡិកា	បួសលេង,

២- ឧបទុស្សិកា	បួសប្រទូស្តសាសនា,

៣- ឧបមុយ្ហិកា	បួសល្ងង់ខ្លៅ,

៤- ឧបជិវិកា	បួសគ្រាន់តែចិញ្ចឹមជីវិត,

៥- ឧបចិណ្ណិកា	បួសសន្សំទ្រព្យទុក,

៦- ឧបនិស្សរណា   បួសដើម្បីវេវៀរខ្លួនឱ្យចេញចាកភព ។

## សាស្តាបព្វជ្ជា ៦ យ៉ាង

| | | | |
|---|---|---|---|
| ១- | ព្រះអង្គ | យកចិត្ត | ជា សីមា, |
| ២- | ព្រះអង្គ | យកបញ្ញា | ជា ឧបជ្ឈាយ៍, |
| ៣- | ព្រះអង្គ | យកសច្ចៈ | ជា កម្មវាចារ្យ, |
| ៤- | ព្រះអង្គ | យកសតិ | ជា អនុស្សាវណ្ណ, |
| ៥- | ព្រះអង្គ | យកបេះដូង | ជា ទេយ្យវត្ថុ, |
| ៦- | ព្រះអង្គ | យកចេតសិក | ជា ព្រះសង្ឃ ។ |

## ហេតុដែលធ្វើឱ្យផែនដីកម្រើកញាប់ញ័រមាន ៨ គឺ

១- ខ្យល់កម្រើក,

២- អ្នកមានឫទ្ធិបណ្តាល,

៣- ព្រះពោធិសត្វចុះចាកតុសិតសួគ៌មកកាន់ព្រះគភ៌,

៤- ព្រះពោធិសត្វប្រសូត្រ,

៥- ព្រះតថាគតត្រាស់ដឹង,

៦- ព្រះតថាគតទ្រង់ដាក់ព្រះជន្មាយុសង្ខារ,

៧- ព្រះតថាគតទ្រង់សម្តែងបឋមទេសនា,

៨- ព្រះតថាគតបរិនិព្វាន ។

## ឆក្ក ពួក ៦

## គារវតា ការគោរព ៦ យ៉ាង

| | | | |
|---|---|---|---|
| ១- | ពុទ្ធគារវតា | គោរពក្នុង | ព្រះពុទ្ធ, |
| ២- | ធម្មគារវតា | គោរពក្នុង | ព្រះធម៌, |
| ៣- | សង្ឃគារវតា | គោរពក្នុង | ព្រះសង្ឃ, |
| ៤- | សិក្ខាគារវតា | គោរពក្នុង | ការរៀនសូត្រ, |
| ៥- | អប្បមាទគារវតា | គោរពក្នុង | សេចក្ដីមិនប្រមាទ, |
| ៦- | បដិសណ្ឋារគារវតា | គោរពក្នុង | បដិសណ្ឋារៈ ។ |

## សារាណីយធម៌ ៦ យ៉ាង

ធម៌ជាទីតាំងនៃសេចក្ដីរឭកហៅថា សារាណីយធម៌មាន ៦ យ៉ាង

១- មេត្តាកាយកម្ម តាំងកាយកម្មប្រកបដោយមេត្តាចំពោះភិក្ខុសាមណេរផងគ្នា ទាំងចំពោះមុខនិងកំបាំងមុខ គឺខ្វល់ខ្វាយនឹងធុរៈផងគ្នាដោយកាយមានជួយព្យាបាល ក្នុងវេលាមានអាពាធដោយមេត្តា,

២- មេត្តាវចីកម្ម តាំងវចីកម្មប្រកបដោយមេត្តាចំពោះភិក្ខុសាមណេរផងគ្នា ទាំងចំពោះមុខនិងកំបាំងមុខ គឺជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈផងគ្នាដោយវាចា មានប្រដៅដាស់

តឿនជាដើម ដោយមេត្តា,

៣- មេត្តាមនោកម្ម តាំងមនោកម្មប្រកបដោយមេត្តា ចំពោះភិក្ខុសាមណេរផងគ្នា ទាំងចំពោះមុខនិងកំបាំងមុខ គឺគិតតែរបស់ដែលជាប្រយោជន៍ឱ្យដល់គ្នា,

៤- លាភៈ ចែកលាភដែលខ្លួនបានមកហើយដោយធម៌ ឱ្យភិក្ខុសាមណេរផងគ្នា មិនហួងហែង ឬត្បិតត្បៀតលាក់លៀម ទុកបរិភោគតែម្នាក់ឯង,

៥- សីលៈ រក្សាសីលបរិសុទ្ធស្មើគ្នា នឹងភិក្ខុសាមណេរដទៃ មិនធ្វើខ្លួនឱ្យជាទីរង្កៀសព្រោះសីលរបស់ខ្លួន,

៦- ទិដ្ឋិ មានសេចក្តីយល់ឃើញត្រូវគ្នា នឹងភិក្ខុសាមណេរដទៃ មិនវិវាទនឹងអ្នកណា ព្រោះហេតុមានសេចក្តីយល់ឃើញជាខុសគ្នាឡើយ ។

ធម៌ ៦ យ៉ាងនេះ រមែងធ្វើអ្នកប្រព្រឹត្តឱ្យជាទីស្រឡាញ់ ជាទីគោរពរបស់អ្នកដទៃប្រព្រឹត្តដើម្បីសង្គ្រោះដល់គ្នានិងគ្នា ដើម្បីមិនវិវាទគ្នា ដើម្បីព្រមព្រៀងគ្នា ។

## អាយតនៈ ខាងក្នុង ៦

ចក្ខុ ភ្នែក, សោតៈ ត្រចៀក, ឃានៈ ច្រមុះ, ជីវ្ហា អណ្តាត, កាយ ខ្លួនប្រាណ, មនោ ចិត្ត, ហៅឥន្ទ្រីយ៍ ៦ ក៏បាន ។

## អាយតនៈខាងក្រៅ ៦

រូបៈ រូប, សទ្ទៈ សំឡេង, គន្ធៈ ក្លិន, រសៈ រស, ផោដ្ឋព្វៈ អារម្មណ៍ដែលប៉ះពាល់ត្រូវកាយ, ធម្មារម្មណៈ អារម្មណ៍ដែលកើតចំពោះចិត្ត ។ ហៅថាអារម្មណ៍ ៦ ក៏បាន ។

## វិញ្ញាណ ៦

រូបប៉ះភ្នែកកើតសេចក្តីដឹងឡើង ហៅថាចក្ខុវិញ្ញាណ, សំឡេងប៉ះត្រចៀក កើតសេចក្តីដឹងឡើងហៅថា សោតវិញ្ញាណ, ក្លិនប៉ះច្រមុះ កើតសេចក្តីដឹងឡើង ហៅថាឃានវិញ្ញាណ, រសប៉ះអណ្តាត កើតសេចក្តីដឹងឡើង ហៅថាជីវ្ហាវិញ្ញាណ ផោដ្ឋព្វៈ ប៉ះកាយកើតសេចក្តីដឹងឡើង ហៅថា កាយវិញ្ញាណ, ធម៌កើតចំពោះចិត្ត កើតសេចក្តីដឹងឡើង ហៅថាមនោវិញ្ញាណ ។

## សម្ផស្ស ៦

អាយតនៈខាងក្នុងមានភ្នែកជាដើម អយតនៈខាងក្រៅមានរូបជាដើម

វិញ្ញាណមានចក្ខុវិញ្ញាណជាដើម មកខ្ទប់គ្នាទាំង ៣ នេះហៅថា សម្ផស្ស មានឈ្មោះហៅតាមអាយតនៈខាងក្នុង ៦ គឺចក្ខុសម្ផស្ស, សោតសម្ផស្ស, ឃានសម្ផស្ស, ជីវ្ហាសម្ផស្ស, កាយសម្ផស្ស, មនោសម្ផស្ស ។

## វេទនា ៦

សម្ផស្សជាបច្ច័យឱ្យកើតវេទនា, គឺជាសុខខ្លះ ទុក្ខខ្លះ មិនសុខ, មិនទុក្ខខ្លះ មានឈ្មោះហៅថាអាយតនៈខាងក្នុង៦ គឺកើតផ្លូវភ្នែកហៅចក្ខុសម្ផស្សជាវេទនា, កើតផ្លូវត្រចៀកហៅសោតសម្ផស្សជាវេទនា កើតផ្លូវច្រមុះហៅឃានសម្ផស្សជាវេទនា, កើតផ្លូវអណ្តាត ហៅជីវ្ហាសម្ផស្សជាវេទនា, កើតផ្លូវកាយ ហៅកាយសម្ផស្សជាវេទនា, កើតផ្លូវចិត្តហៅមនោសម្ផស្សជាវេទនា ។

## ធាតុ ៦

១- បឋវីធាតុ ធាតុដី, ២- អាបោធាតុ ធាតុទឹក, ៣- តេជោធាតុ ធាតុភ្លើង, ៤- វាយោធាតុ ធាតុខ្យល់, ៥- អាកាសធាតុ ចន្លោះដែលមានក្នុងកាយ, ៦-វិញ្ញាណធាតុ សេចក្តីដឹងអ្វីៗ បាន ។

## ពួកការាយរង៍

## គុណសម្បត្តិនៃបុគ្គលជានាយកលើគេមាន ៦ យ៉ាង

*១- ខមា* — *មានសេចក្ដីអត់ធន់,*

*២- ជាគរិយៈ* — *មាសេចក្ដីភ្ញាក់រឭកជារឿយៗ គឺរៀងរៃ,*

*៣- ឧដ្ឋានៈ* — *មានសេចក្ដីឧស្សាហ៍ព្យាយាម,*

*៤- សំវិភាគៈ* — *មានសេចក្ដីចែករំលែក,*

*៥- ទយា* — *មានសេចក្ដីអាណិតអាសូរ,*

*៦- ឥក្ខនា* — *មានការពិនិត្យត្រួតត្រាមើល និងការពិចារណាមើល ។*

## អំពីសករាជ

*ពាក្យថា សករាជ មកអំពី សកៈ សំស្ក្រឹតថា សកៈ កាលសម័យ យុគៈ និងរាជស្ដេច បានសេចក្ដីថា ការកំណត់រាប់ឆ្នាំ តាមកំណត់កាល ពីយូររៀងមក ដោយយកបុគ្គលអស្ចារ្យ ឬ ហេតុអស្ចារ្យណាមួយមកជា គោល ក្នុងជំនាន់ដើម គេប្រើត្រឹមសកៈប៉ុណ្ណោះ លុះសម័យក្រោយមក ប្រមាណក្នុងសម័យឧត្តុង្គ ទើបមានប្រើសកៈរាជ ដរាបមកដល់សព្វថ្ងៃ នេះ ។*

## សករាជមាន ៤ យ៉ាង

*១- ព្រះពុទ្ធសករាជ*

២- គ្រឹស្តសករាជ

៣- មហាសករាជ

៤- ចុល្លសករាជ

## ប្រវត្តិពុទ្ធសករាជ

១- ពុទ្ធសករាជជាសករាជដែលរាប់ចំនួនថ្ងៃខែឆ្នាំ តាំងពីថ្ងៃពុធ ១ រោច ខែពិសាខ ឆ្នាំម្សាញ់ ក្រោយថ្ងៃដែលព្រះសាក្យមុនីបរិនិព្វានទៅបាន១ថ្ងៃរៀងមក ព្រះបរមគ្រូបរិនិព្វាននៅថ្ងៃអង្គារ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់ ហេតុនេះបានរាប់ពីត្រឹមថ្ងៃ១រោច ខែឆ្នាំជាមួយនោះ មកជាកេណ្ឌ ពុទ្ធសករាជសរសេរកាត់អក្សរ ព.ស.។

## ប្រវត្តគ្រិស្តសករាជ

២- កើតឡើងក្រោយពុទ្ធសករាជចំនួន៥៤៣ឆ្នាំ ដែលមានសាស្តាចារ្យម្នាក់ឈ្មោះ យេស៊ូ ឬ យេស៊ូគ្រិស្ត ជាអ្នកបង្កើតលទ្ធិសាសនាគ្រដែនឬគ្រិស្ត កើតនៅប្រទេស អ៊ីតាលី ខ្វះថាប្រទេស បាលេស្ទីន ក្នុងសតវត្សទី៦នៃពុទ្ធសករាជ៥៧៦ ក្នុងគំរប់អាយុ៣៣ឆ្នាំ, គ្រិស្តសករាជសរសេរអក្សរកាត់ជា គ.ស.។

## ប្រវត្តិមហាសករាជ

៣- មហាសករាជ កើតឡើងក្នុងរាជព្រះបាទសកៈឬសាលីវាហលៈ

នៅក្នុងប្រទេសឥណ្ឌៀក្នុងរវាង ព.ស.៦២១ ដោយប្រារព្ធយកជ័យជំនះ យ៉ាងសម្បើមរបស់ក្សត្រអង្គនេះជាកេណ្ឌៈ ប៉ុន្តែក្នុងជំនាន់មុនហៅត្រឹម តែសករាជប៉ុណ្ណោះ លុះខាងក្រោយមកមានសករាជថ្មីកើតឡើងហៅថា សករាជព្រះចៅសាលីវាហនៈ មហាសករាជសរសេរ អក្សរកាត់ ម.ស. ក្នុងព្រះរាជពង្សាវតារខ្មែរថាព្រះបាទសម្តេច ព្រះអរិត្តិពលពាហនោ ព្រះកេ-តុមាលាសូរវង្ស័បានតាំងមហាសករាជ១ក្នុងព.ស.៦២១ ព្រះបាទសម្តេចព្រះ សិទ្ធពរអមរិនបរមកិពញាក្រែកបានតាំងសករាជ ១ ក្នុង ព.ស.១១៨១ ។

# ប្រវត្តិចុល្លសករាជ

៤- ក្សត្រយ៍ភូមាទ្រង់ព្រះនាម សង្ឃរាជឬហៅថា ពុពូសោហេរ៍ ជាក្សត្រទី ១៩ ក្នុងវង្សសមុទ្ធិរិទ្ធ ទ្រង់តាំងឡើងក្នុងឆ្នាំកុរហើយរាប់ឆ្នាំជា ឯកសៈ ក្នុងពុទ្ធព.ស. ១១៩២ ដោយយកសុរិយគតិគឺពេល ប្រជួបខួបថ្ងៃ អាទិត្យ ដែលគោចរចេញអំពីមេសារាសី ហើយត្រឡប់ចូលមេសារាសី វិញ ឯការដែលប្រើពាក្យជាឯកស័ក ទោស័ក ត្រីស័ក ចត្វាស័ក បញ្ចស័ក ជា ដើមប្រកបនឹងឈ្មោះឆ្នាំ ក៏កើតឡើងក្នុងវេលាដែលកើត ចុល្វសករាជដែរ ទំនៀមទំលាប់ចូលឆ្នាំក្នុងខែមេសា (អាព្រឹល) គឺត្រូវនិងខែចេត្រតាមចន្ទគតិ ក៏កើតមានឡើងក្នុងសម័យដែលកើត ចុល្វសករាជនេះដែរ ។ សរសេរ កាត់ ច.ល. ។

## សត្តកៈ ពួក ៧
## អបរិហានីយធម៌ ៧ យ៉ាង

ធម៌មិនជាទីតាំងនៃសេចក្ដីសាបសូន្យ គឺប្រព្រឹត្តទៅដើម្បីសេចក្ដីចម្រើនមួយចំណែកប៉ុណ្ណោះហៅថា « អបរិហានីយធម៌ » មាន ៧យ៉ាង

១- ឧស្សាហ៍ប្រជុំគ្នាជារឿយ ៗ,

២- កាលប្រជុំគ្នា ក៏ព្រមព្រៀងគ្នាប្រជុំ, កាលលើកលែងប្រជុំក៏ព្រមព្រៀងគ្នាលើក ទាំងព្រមព្រៀងគ្នាជួយធ្វើករណីកិច្ច ដែលសង្ឃនឹងគប្បីធ្វើផង,

៣- ខណាដែលព្រះពុទ្ធមិនបានបញ្ញត្ត មិនបញ្ញត្តឡើងទាំងមិនដក.ខដែលទ្រង់បញ្ញត្តហើយ សមាទានសិក្សាតាមសិក្ខាបទ ដែលទ្រង់បញ្ញត្តហើយ,

៤- ភិក្ខុណាធំជាប្រធានក្នុងសង្ឃ គោរពរាប់អានភិក្ខុនោះជឿស្ដាប់ពាក្យលោក,

៥- មិនលុះតាមអំណាចចំណង់ដែលកើតឡើង,

៦- ត្រេកអរក្នុងសេនាសនៈស្ងាត់,

៧- តាំងចិត្តគិតថា សព្រហ្មចារី គឺភិក្ខុសាមណេរជាអ្នកមានសីលមិនទាន់មកកាន់អាវាសនេះ សូមឱ្យមក, ដែលមក



WAT KHEMARARATANARAM

ហើយ សូមឱ្យនៅជាសុខសប្បាយ ។

ធម៌៧យ៉ាងនេះ កាលបើបានតាំងនៅក្នុងបុគ្គលណាហើយបុគ្គលនោះមិនមានសេចក្តីសាបសូន្យឡើយ មានតែសេចក្តីចម្រើនប៉ុណ្ណោះ ។

## អរិយទ្រព្យ ៧ យ៉ាង

ទ្រព្យគឺគុណសេចក្តីល្អ ដែលមានក្នុងសន្តានយ៉ាងប្រសើរហៅថា អរិយទ្រព្យមាន ៧ យ៉ាង

១- សទ្ធាធនំ. ទ្រព្យគឺសេចក្តីជឿរបស់ដែលគួរជឿ,

២- សីលធនំ. ទ្រព្យគឺការរក្សាកាយវាចាឱ្យរៀបរយល្អ,

៣- ហិរិធនំ. ទ្រព្យគឺសេចក្តីខ្មាស់អំពើបាប,

៤- ឱត្តប្បធនំ. ទ្រព្យគឺសេចក្តីខ្លាចអំពើបាប,

៥- សុតធនំ. ទ្រព្យគឺភាពជាអ្នកធ្លាប់បានឮ បានស្តាប់ច្រើនជាអ្នកចេះចាំធម៌ និងវិជ្ជាសិល្បៈច្រើន,

៦- ចាគធនំ. ទ្រព្យគឺការលះបែងចែករបស់ខ្លួន ឱ្យដល់បុគ្គលដែលគួរឱ្យ,

៧- បញ្ញាធនំ. ទ្រព្យគឺសេចក្តីដឹងស្គាល់ របស់ដែលជាប្រយោជន៍ និងមិនជាប្រយោជន៍,

អរិយទ្រព្យទាំង៧ប្រការនេះ ល្អជាងទ្រព្យខាងក្រៅ មានមាស

ប្រាក់ជាដើម, គួរស្វែងរកគួរខំប្រឹងសន្សំទុកឱ្យមានក្នុងសន្តាន ។

## សប្បុរិសធម៌ ៧ យ៉ាង

ធម៌របស់សប្បុរស ហៅថា សប្បុរិសធម៌មាន ៧ យ៉ាង

១- ធម្មញ្ញុតា. ភាពជាអ្នកស្គាល់ហេតុ ដូចស្គាល់ថា នេះជាហេតុនៃសេចក្តីសុខ នេះជាហេតុនៃសេចក្តីទុក្ខ ជាដើម ។

២- អត្ថញ្ញុតា. ភាពជាអ្នកស្គាល់ផល ដូចស្គាល់ថា សេចក្តីសុខ សេចក្តីទុក្ខជាផលកើតអំពីហេតុនេះ, នោះ ជាដើម ។

៣- អត្តញ្ញុតា. ភាពជាអ្នកស្គាល់ខ្លួនថា អាត្មាអញនេះមានជាតិត្រកូល, យស, សក្តិ, សម្បត្តិ, បរិវារ, សេចក្តីចេះដឹងគុណធម៌ដែលមានក្នុងខ្លួនត្រឹមតែប៉ុណ្ណោះ ហើយប្រព្រឹត្តគួរដល់ឋានៈរបស់ខ្លួន ។

៤- មត្តញ្ញុតា. ភាពជាអ្នកស្គាល់ប្រមាណ ក្នុងការស្វែងរកគ្រឿងចិញ្ចឹមជីវិតដោយផ្លូវប្រពៃ ព្រមទាំងស្គាល់ប្រមាណក្នុងការបរិភោគ,

៥- កាលញ្ញុតា. ភាពជាអ្នកស្គាល់វេលា ណាដែលគួរនឹងប្រកបកិច្ចការនោះ ៗ,

៦- បរិសញ្ញុតា. ភាពជាអ្នកស្គាល់ប្រជុំជន និងកិរិយាដែលប្រព្រឹត្ត,

ក្នុងទីប្រជុំជននោះៗ ថា ពួកនេះកាលទៅរក ត្រូវធ្វើកិរិយាយ៉ាងនេះៗ ត្រូវនិយាយយ៉ាងនេះៗ,

៧- បុគ្គលបរោបរញ្ញុតា ភាពជាអ្នកស្គាល់បុគ្គលថា អ្នកនេះជាមនុស្សល្អគួរគប់រក, អ្នកនេះជាមនុស្សមិនល្អ មិនគួរគប់រក ជាដើម ។

## សប្បុរិសធម៌ ៧ យ៉ាងទៀត

១- ជាអ្នកមានសទ្ធា ជាអ្នកមានសេចក្ដីខ្មាស់បាប, ជាអ្នកខ្លាចបាប, ជាអ្នកបានឮបានស្ដាប់ច្រើន, ជាអ្នកមានព្យាយាម, ជាអ្នកមានសេចក្ដីខ្ជាប់ខ្ជួន, ជាអ្នកមានបញ្ញា,

២- នឹងព្រឹក្សារឿងអ្វីជាមួយអ្នកណា ក៏មិនព្រឹក្សាដើម្បីបៀតបៀនខ្លួននឹងអ្នកដទៃ,

៣- នឹងគិតរឿងអ្វី ក៏មិនដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ,

៤- នឹងពោលរឿងអ្វី ក៏មិនពោលដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ,

៥- និងធ្វើការអ្វី ក៏មិនធ្វើដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ,

៦- មានសេចក្ដីយល់ឃើញល្អប្រពៃ មានយល់ឃើញថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ជាដើម,

៧- ឱ្យទានដោយគោរព គឺអើពើនឹងរបស់ដែលខ្លួនឱ្យ, រាក់ទាក់

ដល់អ្នកទទួលទាន មិនធ្វើអាការដូចជាបោះចោល ។

## ពោជ្ឈង្គ ៧ យ៉ាង

| | | |
|---|---|---|
| ១- | **សតិ** | សេចក្តីរឭកបាន, |
| ២- | ធម្មវិចយៈ | សេចក្តីពិចារណាជ្រើសរើសរកធម៌, |
| ៣- | វិរិយៈ | សេចក្តីព្យាយាម, |
| ៤- | បីតិ | សេចក្តីឆ្អែតចិត្ត, |
| ៥- | បស្សទ្ធិ | សេចក្តីស្ងប់ចិត្ត, |
| ៦- | សមាធិ | សេចក្តីតាំងចិត្តខ្ជាប់, |
| ៧- | ឧបេក្ខា | សេចក្តីដែលចិត្តព្រងើយ ។ |

ហៅតាមប្រភេទថា សតិសម្ពោជ្ឈង្គៈ ដោយលំដាប់ដល់ឧបេក្ខាសម្ពោជ្ឈង្គៈ ។

# ញូកកាយវង្ស

## ទានផងនិងចាគៈមានសេចក្ដីផ្សេងគ្នាដូច្នេះ គឺ

ទានៈ ប្រែថាឱ្យវត្ថុរបស់ខ្លួន ដែលជាប់ជំពាក់ដោយមច្ឆរិយ សេចក្ដីកំណាញ់ហើយក៏លះវត្ថុនោះឱ្យឈ្មោះថាទាន ។

ចាគៈ ប្រែថាលះវត្ថុដែរប៉ុន្តែផ្សេងគ្នា ចំណែកទានៈ បានខាងឯបច្ច័យ ៤ និងទេយ្យវត្ថុ១០ យ៉ាងប៉ុណ្ណោះថាកិលេសចាគៈ ។

## ទានក្នុងព្រះបរមត្ថមាន ៦ យ៉ាងគឺ

រូបទានឱ្យរូបជាទាន១, សទ្ទទានឱ្យសម្លេងជាទាន១, គន្ធទាន ឱ្យក្លិនជាទាន១, រសទាន. ឱ្យរសជាទាន១, ផោដ្ឋព្វទាន. ឱ្យសម្ផស្សជាទាន១, ធម្មារម្មណ៍. ឱ្យអារម្មណ៍ ដែលកើតតាមមនោទ្វារជាទាន១, ត្រូវជា៦ ។

**ទានមាន ៤ -មាន៦- មាន១០**

## ទានក្នុងព្រះវិន័យមាន ៤ នោះ គឺ

១- ចីវរប្បច្ច័យ សំពត់សម្រាប់ស្លៀកដណ្ដប់របស់បព្វជិត មានអន្តរវាសកជាដើម ។

២- បិណ្ឌបាតប្បច្ច័យ អាហារសម្រាប់បរិភោគរបស់បព្វជិតមានខាទនីយា និងភោជនីយាដែលទទួលទុកបានតាំងពីអរុណរះដល់ថ្ងៃត្រង់ ។

៣- សេនាសនប្បច្ច័យ ទីនៅទីអាស្រ័យរបស់បព្វជិតមានកុដិ សាលាគ្រែ ឬ ស្បែកជើង ក៏ហៅថាសេសនប្បច្ច័យដែរ ។

៤- គិលានប្បកេសជ្ជៈបច្ច័យ ថ្នាំកែរោគសម្រាប់ព្យាបាលជម្ងឺផ្សេងៗ របស់បព្វជិតមានទឹក (បានៈ ៣យ៉ាងនឹងថ្នាំដែលត្រាំដោយទឹកមូត្រជាដើម) ដែលទុកធាន់តាមកំណត់កាលបាន ។

## ទានក្នុងព្រះសូត្រ ១០ នោះគឺ

បានដល់បុញ្ញកិរិយាវត្ថុ ១០យ៉ាង ឬក៏ទានវត្ថុ១០យ៉ាង គឺ អន្នំបាយ១, បានំ ទឹក១, វត្ថំ.សំពត់១, យានំ.យាន១, មាលា. ផ្កា១, គន្ធគ្រឿងក្រអូប១, វិលេបនំ .គ្រឿងលាប១, សេយ្យំ.ទីដេក១, អាវសថំ.ទីនៅ១, បទីបេយ្យំ.គ្រឿងប្រទីប១ ។

## អសម្មតទាន គឺ ទានឥតផល ៥ យ៉ាងគឺ

១- ឥត្ថីទានំ. ឱ្យស្ត្រីដល់បុរស ឬឱ្យបុរសដល់ស្ត្រី,

២- ឧសុភទានំ. លេងគោឈ្មោលឱ្យដល់គោញី លេងគោញីឱ្យដល់គោឈ្មោល,

៣- មជ្ជទានំ. ឱ្យទឹកស្រវឹង,

៤- សមជ្ជទានំ. ឱ្យមហោស្រពគឺរបាំរាំច្រៀងថ្មុកក្រម៉ាច់,

៩- បិត្តកម្មទានំ. ឱ្យទានរូបគំនូរស្ត្រីបុរសដែលជារូបឱ្យកើតសេចក្តីត្រេកតម្រេកទៅរកកាម ។

ទានទាំង ៩ យ៉ាងនេះមិនឱ្យឈ្មោះថាទានឡើយ ។

## អំពីកាលទាន ៥ យ៉ាង

កាលទានប្រែថា ទានឱ្យទៅតាមកាល

១- អាគន្តុកទានំ. ឱ្យទានដល់បុគ្គលទើបមកថ្មី,

២- កមិកទានំ ឱ្យទានដល់អ្នកដំណើរដែលទៅកាន់ផ្លូវឆ្ងាយ ។

៣- គិលានទានំ. ឱ្យទានដល់អ្នកជម្ងឺ,

៤- ទុព្ភិក្ខទានំ. ឱ្យទានក្នុងវេលាអំណត់អត់ឃ្លាន,

៥- នវទានំ. ឱ្យទានទេយ្យវត្ថុដែលទើបនឹងមានដំបូង ។

## អំពី ចាន: ទឹកអដ្ឋបាន ៨ យ៉ាងគឺ

## (ឬភេសជ្ជៈ ៨ យ៉ាង)

១- អម្ពបានំ. ទឹកដែលគេធ្វើដោយផ្លែស្វាយ,

២- ជម្ពុបានំ ទឹកដែលគេធ្វើដោយផ្លែព្រីង,

៣- ចោចបានំ. ទឹកដែលគេធ្វើដោយផ្លៃចេកគ្រាប់,

៤- មោចបានំ. ទឹកដែលគេធ្វើដោយផ្លៃចេកឥតគ្រាប់,

៥- មធុបានំ. ទឹកដែលគេធ្វើដោយផ្លែស្រគុំ,

៦- មុទ្ទិក្កបានំ. ទឹកដែលគេធ្វើដោយផ្លែចន្ទន៍,

៧- សាសុកបានំ. ទឹកដែលគេធ្វើដោយផលជាតិមានព្រលិតក្រហម ក្រឱឈូកជាដើម,

៨- ផុរុសកបានំ. ទឹកដែលគេធ្វើដោយផ្លែម៉ាក់ប្រាង ។

## បានៈទឹក ៨ យ៉ាងទៀត

១- កោសម្ពបានំ. ទឹកដែលគេធ្វើដោយផ្លែសង្ស័រ,

២- កោលបានំ. ទឹកដែលគេធ្វើដោយផ្លែពុទ្រាតូច,

៣- ពទរបានំ. ទឹកដែលគេធ្វើដោយផ្លែពុទ្រាធំ,

៤- ឃតបានំ. ទឹកដែលគេធ្វើដោយទឹកដោះរាវឬទឹកដោះខាប់,

៥- តេលបានំ. ទឹកដែលគេធ្វើដោយប្រេងល្ងជាដើម,

៦- បយោបានំ. ទឹកដែលគេធ្វើដោយទឹកដោះស្រស់,

៧- យាគុបានំ. ទឹកធ្វើដោយបបរ,

៨- រសបានំ. ទឹកដែលគេធ្វើដោយរសជាតិមានបន្លែជាដើម ។

## សម្បទាធម្មជាតិធ្វើទានឱ្យមានផល ៣ យ៉ាងគឺ

១- វត្ថុសម្បទា. ដល់ព្រមដោយវត្ថុ គឺទេយ្យវត្ថុដែលកើត

ឡើងដោយត្រឹមត្រូវតាមធម៌,

២- ចេតនាសម្បទា. ដល់ព្រមដោយចេតនាទាំង៣គឺៈ បុព្វចេ-តនា ១, មុញ្ចនចេតនា ១, អបរាបរៈ-ចេតនា ១,

៣- បូជនិយសម្បទា. ដល់ព្រមដោយបុគ្គលដែលគួរបូជា បដិគ្គាហកៈ អ្នកប្រតិបត្តិត្រឹមត្រូវល្អ,

## បូជាបានផល ១ យ៉ាង គឺ

១- គុណបូជា. បូជាដោយគុណ ។

## បូជាគ្មានផល ៣ យ៉ាងគឺ

១- ភយបូជា. បូជាព្រោះភ័យ,

២- លាភបូជា. បូជាព្រោះលាភ

៣- ញាតិបូជា. បូជាព្រោះញាតិ ។

## ទានប្បភេទ ៣ យ៉ាងគឺ

១- ចាគចេតនា. ចាគៈចេតនាឈ្មោះថាទាន,

២- វិរតិចេតនា. ការវៀចាកឈ្មោះថាទាន,

៣- ទេយ្យធម្មទាន. ទេយ្យធម៌ឈ្មោះថាទាន ។

## ទានប្បភេទ. ៣ យ៉ាង (ទ)

១- ទានបារមី លះបង់ទ្រព្យសម្បត្តិកូនប្រពន្ធជាទាន,

២- ទានឧបបារមី. លះបង់សាច់ឈាមឱ្យជាទាន,

៣- ទានបរមត្ថបារមី. លះបង់ជីវិតឱ្យទៅជាទាន ។

## ទានសម្បត្តិ ៣ យ៉ាងគឺ

១- ខេត្តសម្បត្តិ. ដល់ព្រមដោយខេត្ត,

២- ទេយ្យសម្បត្តិ. ដល់ព្រមដោយទេយ្យទាន,

៣- ចិត្តសម្បត្តិ. ដល់ព្រមដោយចិត្ត ។

## ទានភូមិ ៣ យ៉ាងគឺ

១- សាមីទាន, ២- សហាយទាន, ៣- ទាសទាន ។

## អង្គនៃបិណ្ឌបាតទាន ៣ យ៉ាង

១- វត្ថេន. ឱ្យមានសពត់សម្រាប់ជូត,

២- សមជ្ជនេន. ឱ្យមានអំបោសសម្រាប់បោស,

៣- អកោធេន. ឱ្យថ្នមចិត្តមិនឱ្យក្រោធខឹង ។

## បុព្វភាគទាន ៣ យ៉ាង

១- កាយវិសោធេយ្យ. ឱ្យសំអាតកាយ,

២- វាចាវិសោចេយ្យ. ឱ្យសំអាតវាចា,

៣- មនោវិសោចេយ្យ. ឱ្យសំអាតចិត្ត ។

## លក្ខណៈទាន គ្រឿងបំណាំ ២ យ៉ាង

១- អាបត្តីជានាតិ. ស្គាល់អាបត្តិក្នុងការទទួល,

២- នឧទ្ធច្ចំ, មានចិត្តមិនរាយមាយអណ្តែតអណ្តូង,

## ទានបើអនុលោមរាប់តាមឈ្មោះយញ្ញមាន ៤ គឺ

១- វិរតិសង្ខាតទានំ ទានវិរតិ គឺការវៀរចាក ,

២- និច្ចកត្តសង្ខាតទានំ. ទានគឺនិច្ចកត្ត,

៣- សរណាគមនសង្ខាតទានំ. ទានគឺកិរិយាដល់ព្រមដោយត្រ័យសរណាគមន៍,

៤- បញ្ចសីលសង្ខាតទានំ. ទានគឺកិរិយាកាន់យកនូវនិច្ចសីល ។

## ធម្មទាន ២ យ៉ាង

១- លោកិយធម្មទាន. សម្តែងអំពីសីល.ភាវនា,

២- សិប្បត្តធម្មទាន សម្តែងអំពីអរិយសច្ចទាំង ៤,

## ធម្មទាន ៣ យ៉ាង

១- កថនំ. ពោលនិយាយពន្យល់,

២-	វាចនំ.	បង្រៀន,

៣-	ធម្មទេសនា.	សម្ដែងធម៌ទេសនា ។

## ទានបានមគ្គ ៣ យ៉ាង

១- សោតាបត្តិមគ្គ,

២- សកទាគាមិមគ្គ,

៣- អនាគាមិមគ្គ ។

## ឱ្យទានបញ្ជូនទៅប្រេត-ប្រកបដោយអង្គ ៣ យ៉ាងគឺ

១-	សីលទានំទេតិ.	ឱ្យទានទៅលោកអ្នកមានសីល,

២-	ឧទ្ទិស្សបេត្តានំ.	ឱ្យហើយឧទ្ទិសចំពោះដល់ប្រេតទាំងឡាយ,

៣-	បមោទតិ.	ប្រេតទាំងឡាយបានទទួលអនុមោទនាត្រេកអរ ។

## អដ្ឋកៈ ពួក ៨

## លោកធម៌ ៨ យ៉ាង

ធម៌ដែលគ្របសង្កត់សត្វលោក. សត្វលោកប្រព្រឹត្តទៅតាមធម៌នោះ ហៅថា លោកធម៌ៗ នោះមាន ៨ គឺមានលាភ១, គ្មានលាភ១, មានយស១, គ្មានយស១, និន្ទា១, សរសើរ១, សុខ១, ទុក្ខ១ ។

លោកធម៌ទាំង ៨ នេះណាមួយកើតឡើងគួរពិចារណាថា របស់នេះកើតឡើងហើយដល់អាត្មាអញ សុទ្ធតែរបស់មិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា, គួរឱ្យដឹងពិតតាមធម្មតា កុំឱ្យមកគ្របសង្កត់ចិត្តបាន គឺកុំឱ្យមានសោមនស្សចំពោះអារម្មណ៍ដែលជាទីប្រាថ្នា កុំឱ្យមានទោមនស្សចំពោះអារម្មណ៍មិនជាទីប្រាថ្នា។

## លក្ខណៈវិនិច្ឆ័យធម៌វិន័យ ៨ ប្រការ

១- សរាគាយៈ ធម៌ណាប្រព្រឹត្តទៅដើម្បីតម្រេក,

២- សំយោគាយៈ ធម៌ណាប្រព្រឹត្តទៅដើម្បីប្រកបដោយទុក្ខ,

៣-អាចយាយៈ ធម៌ណាប្រព្រឹត្តទៅដើម្បីសន្សំកិលេស,

៤- មហិច្ឆតាយៈ ធម៌ណាប្រព្រឹត្តទៅដើម្បីប្រាថ្នាធំ,

៥- អសន្តុដ្ឋិយា ធម៌ណាប្រព្រឹត្តទៅដើម្បីមិនសន្តោសចំ-

ពោះរបស់តាមមានតាមបាន,

៦- សង្គណិកាយៈ ធម៌ណាប្រព្រឹត្តទៅ ដើម្បីប្រឡូកប្រឡំ ដោយពួកគណៈ,

៧- កោសជ្ជាយៈ ធម៌ណាប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស,

៨- ទុព្ភរតាយៈ ធម៌ប្រព្រឹត្តទៅ ដើម្បីការចិញ្ចឹមក្រ ។ ធម៌នោះគប្បីដឹងថា មិនមែនជាធម៌វិន័យ មិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាទេ ។

ធម៌ណាប្រព្រឹត្តទៅខុសផ្ទុយគ្នានិងលក្ខណៈ ៨ ប្រការដូចពោលហើយមាន ៨ ប្រការគឺៈ

១- វិរាគាយៈ ប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក,

២- វិសំយោគាយៈ ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ,

៣- អបចយាយៈ ប្រព្រឹត្តទៅដើម្បីមិនសន្សំកិលេស,

៤- អប្បិច្ឆតាយៈ ប្រព្រឹត្តទៅដើម្បីប្រាថ្នាតិច,

៥- សន្តុដ្ឋិយា ប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរចំពោះវត្ថុតាមមានតាមបាន,

៦- បវិវេកាយៈ ប្រព្រឹត្តទៅដើម្បីស្ងាត់ចាកពួកគណៈ,

៧- វិរិយារម្ភាយៈ    ប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម,

៨- សុករតាយៈ    ប្រព្រឹត្តទៅដើម្បីការចិញ្ចឹមជីវិតងាយ ។

ធម៌នោះគប្បីដឹងថាជាធម៌វិន័យជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា

## មគ្គមានអង្គ ៨

១- សម្មាទិដ្ឋិ    បញ្ញាឃើញប្រពៃ គឺឃើញអរិយសច្ច ៤,

២- សម្មាសង្កប្បៈ    ត្រិះរិះប្រពៃ គឺត្រិះរិះនឹងចេញចាកកាម១.ត្រិះរិះក្នុងការមិនជាហេតុឱ្យកើតព្យាបាទ១, ត្រិះរិះក្នុងការមិនជាហេតុបៀតបៀន១,

៣- សម្មាវាចា.    វាចាប្រពៃ គឺវៀរចាកវចីទុច្ចរិត ៤,

៤- សម្មាកម្មន្តៈ    ការងារប្រពៃ គឺវៀរចាកកាយទុច្ចរិត ៣,

៥- សម្មអាជីវៈ    ចិញ្ចឹមជីវិតប្រពៃ គឺវៀរចាកការចិញ្ចឹមជីវិតដោយផ្លូវខុស,

៦- សម្មាវាយាមៈ    ព្យាយាមប្រពៃ គឺព្យាយាមក្នុងទី ៤ ស្ថានមានព្យាយាមការពារ មិនឱ្យបាបអកុសលកើតឡើងក្នុងសន្តានជាដើម,

៧- សម្មាសតិ    រឭកប្រពៃ គឺរឭកក្នុងសតិប្បដ្ឋាន ៤,

៨- សម្មាសមាធិ.    តាំងចិត្តខ្ជាប់ប្រពៃ គឺចម្រើនឈាន ៤,

ក្នុងអដ្ឋមគ្គទាំង ៨ នេះ សម្មាទិដ្ឋិ, សម្មាសង្កប្បៈ សង្គ្រោះចូលក្នុងបញ្ញាសិក្ខា, សម្មាវាចា, សម្មាកម្មន្តៈ, សម្មាអាជីវៈ សង្គ្រោះចូលក្នុងសីលសិក្ខា, សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ, សង្គ្រោះចូលក្នុងចិត្តសិក្ខា ។

ដំណឹងសៀវភៅចេញថ្មី

សៀវភៅធាតុសង្គ្រោះ ដែលមានពន្យល់អំពីធាតុដែលជាកិរិយាស័ព្ទ នាមស័ព្ទ គុណស័ព្ទ និងអព្យយស័ព្ទ ដែលមានចំនួនធាតុដល់ទៅ ១៦២៥ ធាតុ ដោយការៀបរៀងរបស់ អ៊ុម គយ អតីតក្រុមជំនុំព្រះត្រៃបិដក មានចេញលក់ហើយ ។

# ៣.ករាយវគ្គ

## អំពីឱវាទ

ឱវាទ ប្រែថា ពាក្យប្រៀនប្រដៅ ។ ឱវាទនិងសាសនៈមាន សេចក្តីផ្សេងគ្នាដូច្នេះគឺៈ

ឱវាទបានខាងពាក្យប្រៀនប្រដៅចំពោះមុខ ដូចជាព្រះអង្គទ្រង់ឱ្យប្រជុំពួកភិក្ខុ ហើយទ្រង់ប្រៀនប្រដៅ សម្តែងឱវាទប្បាតិមោក្ខ ជាដើមហៅថាឱវាទ ។ បានតែព្រះអង្គសម្តែងដោយព្រះឯងតែម្យ៉ាង មិនទូទៅដល់សាវកឡើយ ។ ចំណែកសាសនៈនោះ បានដល់ការប្រៀនប្រដៅ ជាសាធារណៈទូទៅបានដល់ពាក្យប្រៀនប្រដៅ ខាងក្រៅក៏ហៅថាសាសនៈដែរ ពុទ្ធោវាទក៏ហៅថាសាសនៈដែរ ពួកសាវកដទៃប្រៀនប្រដៅក៏ហៅថាសាសនៈដែរ មានសេចក្តីផ្សេងគ្នាដូចវិសជ្ជនាមកនេះ ។

## អំពីគុណរបស់ព្រះពុទ្ធ ៣ យ៉ាង

១- បញ្ញាគុណ,

២- វិសុទ្ធិគុណ,

៣- ករុណាគុណ,

## ព្រះពុទ្ធមាន ៤ យ៉ាង

១- ព្រះសព្វញ្ញុពុទ្ធ

២- ព្រះអនុពុទ្ធ

៣- ព្រះសាវកពុទ្ធ

៤- ព្រះបច្ចេកពុទ្ធ

## ព្រះពុទ្ធតេជះមាន ៥ យ៉ាង

១- សីលតេជៈ

២- គុណតេជៈ

៣- បុញ្ញតេជៈ ក្នុងធម្មបទបច្ឆិមភាគ ។

៤- បញ្ញាតេជៈ

៥- ធម្មតេជៈ

## តំណាងព្រះពុទ្ធ ៥ អង្គ

១- ព្រះពុទ្ធរូប, ២- ពោធិព្រឹក្ស, ៣- ព្រះសថូប, ៤- ព្រះធាតុ, ៥- ព្រះត្រ័យបិដក ។

## អំពីពុទ្ធកិច្ចរបស់ព្រះសម្ពុទ្ធ ៥ យ៉ាង

ពុទ្ធកិច្ច ប្រែថាកិច្ចដែលព្រះអង្គត្រូវធ្វើ ឬ ត្រូវប្រព្រឹត្តៈ

១- បុព្វណ្ហេបិណ្ឌបាតំ. ទ្រង់បិណ្ឌបាតក្នុងវេលាព្រឹក,

២- សាយណ្ហេធម្មទេសនំ. ទ្រង់សម្ដែងធម៌ក្នុងវេលាល្ងាច,

៣- បទោសេភិក្ខុឱវាទំ. ទ្រង់ប្រទានឱវាទដល់ភិក្ខុក្នុងវេលាព្រលប់,

៤- អឌ្ឍរត្តេទេវបញ្ហានំ. ទ្រង់ដោះប្រស្នាទេវតាវេលាអធ្រាត្រ,

៥- បច្ចូសេវគតេកាលេភព្វាភព្វេវិលោកនំ ទ្រង់ពិចារណាមើលឧបនិស្ស័យនៃសត្វដែលគួរត្រាស់ដឹងមិនគួរត្រាស់ដឹង ក្នុងវេលាបែកបច្ចូសជិតភ្លឺ ។

## សម្បត្តិព្រះពុទ្ធមាន ៨ យ៉ាង

១- មនុស្សត្តំ. ពេញទីជាមនុស្សភាព,

២- លិង្គសម្បត្តិ. បរិបូណ៌ដោយភេទបុរស,

៣--ហេតុ. អាចកាន់យកនូវព្រះអរហត្តក្នុងអត្តភាព,

៤- សត្ថារទស្សនំ. បានជួបនឹងព្រះពុទ្ធអង្គ,

៥- បព្វជ្ជា. បានចេញបួសក្នុងសាសនាព្រះពុទ្ធ,

៦- គុណសម្បត្តិ. បរិបូណ៌ដោយគុណគឺមិនមានវិកលវិការ,

៧- អធិការោ. បរិបូណ៌ដោយកុសល មានទានជាដើម,

៨- ឆន្ទតា. ស្រលាញ់ចង់បានចំពោះសម្ពោធិញ្ញាណ ។



WAT KHEMARARATANARAM

## សុភាសិត ៤ យ៉ាង

១- ពុទ្ធភាសិត. ភាសិតដែលព្រះពុទ្ធសម្តែង

២- សាវកភាសិត. ភាសិតដែលសាវកសម្តែង

៣- ឥសីភាសិត. ភាសិតដែលឥសីសម្តែង

៤- ទេវតាភាសិត. ភាសិតដែលទេវតាសម្តែង ។

## បិដកមាន ៣ យ៉ាងគឺ

បិដក ប្រថា កញ្ជើ កញ្ជ្រែង ឬ កន្ត្រក មានភាជនៈផ្សេងៗ សម្រាប់ដាក់វត្ថុនានា ។

១- ព្រះវិន័យបិដក មានធម្មក្ខន្ធ ២១ ,០០០ ធម្មក្ខន្ធ

២- ព្រះសុត្តន្តបិដក មានធម្មក្ខន្ធ ២១,០០០ ធម្មក្ខន្ធ

៣- ព្រះអភិធម្មបិដក មានធម្មក្ខន្ធ ៤២,០០០ ធម្មក្ខន្ធ ។

(ក) ព្រះវិន័យបិដក ជាកិច្ចការហាមប្រាមកាយនិងវាចា មិនឱ្យប្រព្រឹត្តល្មើសក្នុងសិក្ខាបទតូចធំ ជាគ្រឿងការពារមិនឱ្យសេចក្តីបៀតបៀនឈ្លោះទាស់ទែងគ្នា ដើម្បីរក្សាកិរិយាមារយាទឱ្យមានរបៀបរៀបរយល្អ ។

(ខ) ព្រះសូត្រជាច្បាប់ហាត់មាត់ នឹងអធ្យាស្រ័យឱ្យរឹងរឹតតែល្អឡើងទៀតដោយផ្សាយមេត្តាចិត្តស្រលាញ់រាប់អានគ្នា ដើម្បីឱ្យសេច-

ក្តីព្រមព្រៀងគ្នាស្មោះស្មើដល់គ្នានឹងគ្នា ។

(គ) ព្រះអភិធម្មជាច្បាប់ផុះខាត់លុបលាងសន្តានចិត្ត ដើម្បីត្រាស់ដឹងនូវមគ្គនិងផល ឬជាគ្រឿងបំបែករូបធាតុ មានវិញ្ញាណធាតុជាដើម ឱ្យឃើញជាក់ស្តែងដល់ចិត្ត ដើម្បីនឹងសម្ព័ន្ធ ចងធាតុផ្សំផ្គុំលាយគ្នា ប្រើការផ្សេងៗ ឱ្យសម្រេចតាមបំណង អ្នកឆ្លៀវឆ្លាសប្រតិពលក្នុងធាតុហៅថាធាតុកោសល ។

## ឫសគល់ព្រះសូត្រមាន ៣

១- ទាន, ២- សីល, ៣- ភាវនា ។

## ឫសគល់ព្រះវិន័យមាន ៣

១- សីល, ២- សមាធិ, ៣- បញ្ញា ។

## ឫសគល់ព្រះអភិធម្មមាន ៣

១- លោភៈ, ២- ទោសៈ, ៣- មោហៈ ។

## ធម៌ប្រៀបធៀប ៨ យ៉ាង

១- សទ្ធា, ដូចជា នឹម,

២- ហិរិ, ដូចជា ខ្សែចន្ទោល,

៣- មនោ, ដូចជា ខ្សែបរ,

៤- សតិ ដូចជា នាយសារថី,

៥- សីល ដូចជា គ្រឿងប្រដាប់រថ,

៦- ឈាន ដូចជា ភ្លៅ,

៧- វីរិយៈ ដូចជា កង់,

៨- ឧបេក្ខា ដូចជា កំណល់នឹម ។

## ដំណឹងសៀវភៅចេញថ្មី

សៀវភៅធាតុសង្គ្រោះ ដោយការរៀបរៀងរបស់ អ៊ុម-គយ អតីតក្រុមជំនុំព្រះត្រៃបិដក មានចេញកល់ហើយ ។

## នវកៈ ពួក ៩

### មលៈ «មន្ទិល» ៩ យ៉ាង

*កោធៈ ក្រោធ១, មក្ខៈ រមិលគុណគេ១, ឥស្សា ឫស្យា១, មច្ឆរិយៈ កំណាញ់១, មាយា មាយា១, សាថេយ្យ ពោលអួត១, មុសា ពោលកុហក១, បាបិច្ឆៈ ប្រាថ្នាអាក្រក់១, មិច្ឆាទិដ្ឋិ ឃើញខុស១ ។*

### ពួកភាយវេជ

### អ្នកប្រាជ្ញតែងប្រកបដោយធម៌ ៤ យ៉ាង

*១- សុតៈ ស្តាប់,*

*២- ចិន្តៈ គិត,*

*៣- បុច្ឆា សួរ,*

*៤- លិខិត សរសេរ ឬ កត់សម្គាល់ បាលីថាៈ*

*សុ.ចិ.បុ.លិ អ្នកប្រាជ្ញប្រែថា អ្នកដែលមិនញុំាងប្រយោជន៍ខ្លួន និង ប្រយោជន៍អ្នកដទៃមិនឱ្យសាបសូន្យឈ្មោះថា អ្នកប្រាជ្ញ ។*

### ហេតុដែលនាំឱ្យអាយុៈខ្លី ៥ យ៉ាង

*១- អសប្បាយការី មិនធ្វើខ្លួនឱ្យសប្បាយ,*

*២- អសប្បាយ មត្តំ ជានាតិ ដឹងប្រមាណក្នុងការសប្បាយ,*

៣- អបរិណតភោជំ បរិភោគអាហារភ្លើងធាតុធ្វើឱ្យរលួយមិនទាន់

៤- អកាលចារី ដើរលេងខុសកាល,

៥- អព្រហ្មចារី ប្រព្រឹត្តធម៌មិនប្រសើរល្មោភក្នុងកាម ។

## ហេតុដែលនាំឱ្យអាយុវែង ៥ យ៉ាង

១- សប្បាយការី. ធ្វើខ្លួនឱ្យសប្បាយ,

២- សប្បាយេមត្តំជានាតិ. ដឹងប្រមាណក្នុងការសប្បាយ,

៣- បរិណតភោជី. បរិភោគអាហារល្មមភ្លើងធាតុធ្វើ
ឱ្យរលួយស្រួល,

៤- កាលចារី ដើរលេងក្នុងការគួរ,

៥- ព្រហ្មចារី. ប្រព្រឹត្តធម៌ប្រសើរមិនល្មោភក្នុងកាម ។

## ឆ្កួតមាន ៨ យ៉ាង

១- កាមុម្មត្តកោ. ឆ្កួតអំពី កិលេសកាមនិងវត្ថុកាម,

២- ទោសុម្មត្តកោ. ឆ្កួតអំពី ទោសៈ,

៣- មោហុម្មត្តកោ. ឆ្កួតអំពី សេចក្តីវង្វេង,

៤- មកុម្មត្តកោ ឆ្កួតអំពី សេចក្តីស្រវឹង,

៥- ទិដ្ឋុម្មត្តកោ. ឆ្កួតអំពី ទិដ្ឋិយល់ខុស,

៦- មិត្តមត្តកោ.     ឆ្លួតអំពី    ប្រមាត់ឆ្លួតជម្មតា,

៧- យក្ខម្មត្តកោ.    ឆ្លួតអំពី    ខ្វះចូល,

៨- ព្យស្សនុម្មត្តកោ.ឆ្លួតអំពី    លោភៈ       ដោយអន្តរាយព្រាត់ប្រាសទ្រព្យសម្បត្តិ ។

## អំពីមនុស្សដោយរូបមាន ៥ យ៉ាង

១-  មនុស្សនិយតោ.  បានដល់ពួកមនុស្សដែលមានសញ្ញាតិចដូចជាសត្វនរក ។

២-  មនុស្សបេតោ.  បានដល់ពួកមនុស្សមានសញ្ញាតិដូចជាប្រេត  ។

៣- មនុស្សតិរច្ឆានោ. បានដល់ពួកមនុស្សមានសញ្ញាតិដូចជាតិរច្ឆាន ។

៤-  មនុស្សមនុសោ  ឬមនុស្សភូតោ  បានដល់ពួកមនុស្សមានសញ្ញាតិដូចជាមនុស្ស ។

៥- មនុស្សទេវោ. បានដល់មនុស្សទេវតា ៦ជាន់ ពីត្រឹមជាន់ទី១ ដល់ ទី៣ ជាមនុស្សថោកទាប ពីត្រឹមទី៤ ដល់ ទី៥ ជាមនុស្សជាន់ខ្ពស់ ។

## អរិយសច្ចទាំង ៤ មានសេចក្តីផ្សេងៗគ្នាដូច្នេះគឺ

១- ទុក្ខសច្ច      ជាកុសលខ្វះ ជាអកុសលខ្វះ អព្យាក្រិតខ្វះ,

២- សមុទយសច្ច    ជាអកុសលសុទ្ធ,

៣- និរោធសច្ច         ជាអព្យាកតៈ,

៤- មគ្គសច្ច.         ជាកុសល ។

## ធម៌ធ្វើឱ្យជួបគ្នាមាន ៤ យ៉ាងគឺ

១- សមសទ្ធា         មានសទ្ធាស្មើគ្នា,

២- សមសីលា.         មានសីលស្មើគ្នា,

៣- សមចាគា.         មានការបរិច្ចាគស្មើគ្នា,

៤- សមបញ្ញា.         មានបញ្ញាត្រិះរិះស្មើគ្នា ។

## អំពីមរណៈ មាន២ មាន៣ មាន ៤ យ៉ាងគឺ

**មរណៈ** ប្រែថាស្លាប់ មច្ចុក៏ស្លាប់ដែរ ប៉ុន្តែមរណៈជាធម្មាទិដ្ឋាន មច្ចុជាបុគ្គលាទិដ្ឋាន ។

១- កាលមរណៈ ស្លាប់ទៅតាមកាលគឺស្លាប់ទៅដោយអស់អាយុខ័យ ។

២- អកាលមរណៈ ស្លាប់ខុសកាលដូចធ្លាក់ពីលើផ្ទះ ខ្លាខាំ ក្របីវែធជាដើម ។

## ស្លាប់ ៣ យ៉ាង

១- សតិមរណៈ         ស្លាប់សតិមុន,

២- ខណិកមរណៈ   ស្លាប់ ១ ខណៈចិត្ត ១ខណៈចិត្ត,

៣- សុមុច្ឆេទមរណៈ ស្លាប់យ៉ាងដាច់ខាត គឺមិនកើតទៀតបានដល់ព្រះអរិយបុគ្គល ។

## ស្លាប់ ៤ យ៉ាង ទៀត

១- *អាយុក្ខមរណៈ* *ស្លាប់ដោយអស់អាយុ,*

២- *កម្មក្ខមរណៈ* *ស្លាប់ដោយអស់កម្ម,*

៣- *ឧភយក្ខមរណៈ* *ស្លាប់ដោយអស់អាយុនិងកម្ម,*

៤- *ឧបច្ឆេទកកម្មុនា.* *ស្លាប់ដោយកម្មចូលមកផ្តាច់បង់ ។*

## សេចក្តីស្លាប់នេះពាក្យនិយាយ

## ផ្លាស់ប្តូរគ្នាទីតាមឋានៈរបស់ខ្លួន

*បើព្រះសម្មាសម្ពុទ្ធគេហៅថាចូលបរិនិព្វាន បើព្រះរាជាវិញគេហៅថាសោយទីវង្គត បើព្រះអគ្គមហេសីហៅថាសោយព្រះពិលាល័យ បើមនុស្សសាមញ្ញប៉ុន្តែមិនបរិបូរដោយសីលធម៌និងសម្បត្តិគេហៅថា ទទួលអនិច្ចធម្មឬអនិច្ចកម្ម បើមនុស្សសាមញ្ញប៉ុន្តែពុំសូវបរិបូណ៌ដោយសីលធម៌និងគុណសម្បត្តិទេគេហៅថាស្លាប់ បើសត្វតិរច្ឆាន ឬរុក្ខជាតិនានា ឈើព្រៃវិញគេហៅថាងាប់ ។*

## បុគ្គលដែលព្រះធរណីស្រូប

*ក្នុងពុទ្ធកាលនេះមាន ៥ នាក់គឺៈ*



WAT KHEMARARATANARAM

| | |
|---|---|
| ១- សុប្បពុទ្ធសក្យរាជ | ព្រោះទោសបិទផ្លូវជាទីគោចរនៃព្រះពុទ្ធ, |
| ២- ទេវទត្ត | ព្រោះទោសសង្ឃភេទជាដើម, |
| ៣- នាងចេញ្ចាមាណវិកា | ព្រោះទោសធ្វើឧបាយបង្ខូចព្រះពុទ្ធដោយអសទ្ធម្មជារឿងមិនពិត, |
| ៤- នន្ទិយៈ | ព្រោះប្រហារព្រះសារីបុត្រ, |
| ៥- អជាតសត្តុរាជ | ព្រោះទោសសម្លាប់បិតាឯង ។ |


ដំណឹងសៀវភៅចេញថ្មី

សៀវភៅធាតុសង្គ្រោះ ដោយការរៀបរៀងរបស់ អ៊ុម-គយ អតីតក្រុមជំនុំព្រះត្រៃបិដក, មានចេញលក់ហើយ ។

## ទសកៈពួក ១០

# អកុសលកម្មបថ ១០

*ចាត់ជាកាយកម្ម គឺដោយកាយ ៣ យ៉ាង*

១- *បាណាតិបាត* *ធ្វើជីវិតសត្វឱ្យធ្លាក់ចុះ គឺសម្លាប់សត្វ,*

២- *អទិន្នាទាន.* *កាន់យករបស់ដែលម្ចាស់គេមិនបានឱ្យ,*

៣- *កាមេសុមិច្ឆាចារ* *ប្រព្រឹត្តខុសក្នុងកាម ។*

ចាត់ជាវចីកម្ម គឺធ្វើដោយវាចា ៤ យ៉ាង

១- *មុសាវាទ.* *និយាយកុហក,*

២- *បិសុណាវាចា.* *និយាយញុះញង់គេ,*

៣- *ផរុសវាចា.* *និយាយចាក់ដោតគេ,*

៤- *សម្ផប្បលាបៈ* *និយាយពាក្យឥតប្រយោជន៍ ។*

ចាត់ជាមនោកម្ម គឺធ្វើដោយចិត្ត ៣ យ៉ាង

១- *អភិជ្ឈា* *សម្លឹងរំពៃចង់បានរបស់គេ,*

២- *ព្យាបាទ* *ចងចិត្តគុំគួនគេ,*

៣- *មិច្ឆាទិដ្ឋិ* *ឃើញខុសចាកគន្លងធម៌ ។*

កម្ម ១០ យ៉ាងនេះ ជាផ្លូវបាប មិនគួរប្រព្រឹត្តទេ

## កុសលកម្មបថ ១០

## បាត់ជាកាយកម្ម ៣ យ៉ាង

១- បាណាតិបាតា វេរមណី វៀរចាកធ្វើនូវជីវិតសត្វឱ្យធ្លាក់ចុះ

២- អទិន្នាទានា វេរមណី វៀរចាកកាន់យករបស់ដែល ម្ចាស់គេមិនបានឱ្យ,

៣- កាមេសុមិច្ឆាចារា វេរមណី វៀរចាកប្រព្រឹត្តខុសក្នុងកាម,

## បាត់ជាវចីកម្ម ៤ យ៉ាង

១- មុសាវាទា វេរមណី វៀរចាកនិយាយកុហក,

២- បិសុណាយ វាចាយ វេរមណី វៀរចាកនិយាយញុះញង់,

៣- ផរុសាយ វាចាយ វេរមណី វៀរចាកនិយាយចាក់ដោត,

៤- សម្ផប្បលាបា វេរមណី វៀរចាកនិយាយពាក្យឥតប្រយោជន៍

## បាត់ជាមនោកម្ម ៣ យ៉ាង

១- អនភិជ្ឈា មិនសម្លឹងរំពៃចង់បានទ្រព្យរបស់គេ,

២- អព្យាបាទោ មិនគំនុំគុំគួនគេ,

៣- សម្មាទិដ្ឋិ ឃើញត្រូវតាមគន្លងធម៌ ។

កម្ម ១០យ៉ាងនេះ ជាផ្លូវបុណ្យគួរប្រព្រឹត្ត ។

# បុញ្ញកិរិយាវត្ថុ ១០ យ៉ាង

១- ទានមយៈ បុណ្យសម្រេចដោយបរិច្ចាគទាន,

២- សីលមយៈ បុណ្យសម្រេចដោយការរក្សាសីល,

៣- ភាវនាមយៈ បុណ្យសម្រេចដោយការភាវនា,

៤- អបចាយនមយៈ បុណ្យសម្រេចដោយកាប្រព្រឹត្តឱនលំទោន,

៥- វេយ្យាវច្ចមយៈ បុណ្យសម្រេចដោយការជួយខ្វល់ខ្វាយក្នុងកល្យាណកិច្ច,

៦- ធម្មទេសនាមយៈ បុណ្យសម្រេចដោយការសម្តែងធម៌,

៧- ធម្មស្សវនមយៈ បុណ្យសម្រេចដោយការស្តាប់ធម៌,

៨- បត្តិទានមយៈ បុណ្យសម្រេចដោយការឱ្យចំណែកបុណ្យ,

៩- បត្តានុមោទនាមយៈ បុណ្យសម្រេចដោយការអនុមោទនាចំណែកបុណ្យ,

១០- ទិដ្ឋុជុកម្មៈ ការធ្វើសេចក្តីឃើញឱ្យត្រង់តាមការណ៍ពិត ។

# អភិណ្ហប្បច្ចវេក្ខណៈ

ធម៌ដែលបព្វជិត គួរពិចារណារឿយៗ ហៅថា



WAT KHEMARARATANARAM

## អភិណ្ហប្បច្ចវេក្ខណៈមាន ១០ យ៉ាង

១- វេវណ្ណិយម្ហិ អជ្ឈុបគតោ អាត្មាអញមានភេទផ្សេងអំពីគ្រហស្ថ ហើយអាការកិរិយាណារបស់សមណៈ អាត្មាអញត្រូវប្រព្រឹត្តធ្វើអាការកិរិយានោះ,

២- បរប្បដិពន្ធា មេ ជីវិតា ការចិញ្ចឹមជីវិតរបស់អាត្មាអញជាប់ដោយសារអ្នកដទៃ អាត្មាអញគួរធ្វើខ្លួនឱ្យគេចិញ្ចឹមងាយ,

៣- អញ្ញោ មេ អាកប្បោ ករណីយោ អាការកិរិយាកាយវាចាយ៉ាងដទៃៗ ដែលអាត្មាអញ នឹងត្រូវប្រព្រឹត្តឱ្យល្អជាងនេះនៅមានទៀត,

៤- កច្ចិនុខោ មេ អត្តា សីលតោ ឧបវទតិ ខ្លួនអាត្មាអញមិនតិះដៀលខ្លួនឯងព្រោះសីល (មិនបរិបូណ៌) បានដែរឬទេ ?

៥- កច្ចិនុខោ មំ អនុវិច្ចវិញ្ញូ សព្រហ្មចារីសីលតោ ន ឧបវទន្តិ ពួកសព្រហ្មចារីអ្នកដឹងទាំងឡាយពិចារណាហើយ មិនតិះដៀលអាត្មាអញព្រោះសីល (មិនបរិបូណ៌) បានដែរឬទេ ?

៦- សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អាត្មាអញគង់តែនឹងព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារជាទី

ស្រលាញ់ពេញចិត្តទាំងអស់,

៧- កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ. អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាវផ្ទាន់ឬជាទ្រព្យមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងនឹកឃើញ អាត្មាអញធ្វើនូវកម្មឯណា ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញជាអ្នកទទួលនូវផលនៃកម្មនោះពុំខាន ។

៨- កថម្ភូតស្ស មេ រត្តិន្ទិវា វតិបតន្តិ ថ្ងៃនិងយប់កន្លងទៅឥឡូវនេះអាត្មាអញបានធ្វើអ្វីខ្លះហើយ,

៩- កច្ចិន្នុខោហំ សុញ្ញាគារេ អភិរមាមិ អាត្មាអញត្រេកអរក្នុងផ្ទះស្ងាត់ដែរ ឬទេ ?

១០- អត្ថិ នុខោ មេ ឧត្តរិមនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ សោហំ បច្ឆិមេ កាលេ សព្រហ្មចារីហិ បុដ្ឋោ នមង្កុ ភវិស្សាមិ ឧត្តរិមនុស្សធម្ម គឺធម៌ជារបស់មនុស្សដ៏ប្រសើរក្រៃលែង របស់អាត្មាអញមានទេ ធម៌វិសេសដែលគួរនឹងឃើញដោយប្រាជ្ញា,

អរិយៈ ជាធម៌ដ៏អាចនឹងកំចាត់បង់នូវកិលេស អាត្មាអញបាន ត្រាស់ដឹងហើយ ឬ នៅឡើយទេ ? អាត្មាអញដែលមានធម៌វិសេសបានហើយនោះ បើពួកសព្រហ្មចារីមកសួរក្នុងកាលជាទីបំផុត គឺក្នុងកាលជិតនឹងមរណៈនោះ តើអាត្មាអញនឹងមិនអៀនខ្មាសទេឬ ?

## នាថករណធម៌ៈ ធម៌ធ្វើទីពឹង ១០ យ៉ាង

១- សីលៈ រក្សាកាយវាចាឱ្យរៀបរយ,

២- ពាហុសច្ចៈ ជាអ្នកបានរៀនបានស្ដាប់ច្រើន,

៣- កល្យាណមិត្តតា ជាអ្នកមានមិត្តសម្លាញ់ល្អ,

៤- សោវចស្សតា ជាអ្នកដែលគេប្រដៅងាយ,

៥- កឹករណីយេសុ ទក្ខតា ជាអ្នកប៉ិនប្រសប់ព្រមទាំងឧស្សាហ៍យកចិត្តទុកដាក់ជួយក្នុងកិច្ចធុរៈរបស់ភិក្ខុសាមណេរផងគ្នា

៦- ធម្មកាមតា ជាអ្នកស្រលាញ់ធម៌,

៧- វិរិយៈ ព្យាយាមលះសេចក្ដីអាក្រក់ ប្រព្រឹត្តសេចក្ដីល្អ,

៨- សន្តុដ្ឋិ សន្ដោសចំពោះបច្ច័យ ៤ តាមមានតាមបាន,

៩- សតិ ចាំការដែលបានធ្វើ និងពាក្យដែលបានពោលហើយសូម្បីយូរអង្វែង,

១០- បញ្ញា. ដឹងសេចក្តីប្រព្រឹត្តទៅនៃកងសង្ខារ ។

## កថាវត្ថុ ពាក្យដែលគួរពោល ១០ យ៉ាង

១- អប្បិច្ឆកថា ពាក្យដែលនាំឱ្យមានប្រាថ្នាតិច,

២- សន្តុដ្ឋិកថា ពាក្យនាំឱ្យមានសន្តោសត្រេកអរចំពោះ
បច្ច័យ ៤ តាមមានតាមបាន,

៣- បវិវេកកថា ពាក្យដែលនាំឱ្យស្ងាត់កាយ ស្ងាត់ចិត្ត,

៤- អសំសគ្គកថា ពាក្យដែលនាំមិនឱ្យច្រឡូកច្រឡំដោយពួកគណៈ,

៥- វីរិយារម្ភកថា ពាក្យដែលនាំឱ្យប្រារព្ធព្យាយាម,

៦- សីលកថា ពាក្យដែលនាំឱ្យតាំងនៅក្នុងសីល,

៧- សមាធិកថា ពាក្យដែលនាំឱ្យធ្វើចិត្តឱ្យស្ងប់,

៨- បញ្ញាកថា ពាក្យដែលនាំឱ្យកើតបញ្ញា,

៩- វិមុត្តិកថា ពាក្យដែលនាំឱ្យធ្វើចិត្តឱ្យផុតចាកកិលេស,

១០- វិមុត្តិញ្ញាណទស្សនកថា ពាក្យដែលនាំឱ្យកើតសេចក្តីដឹងឃើញ
ក្នុងការណ៍ដែលចិត្តផុតចាកកិលេស។

## អនុស្សតិ អារម្មណ៍ដែលគួររឭក ១០ យ៉ាង

១- ពុទ្ធានុស្សតិ រឭកដល់គុណព្រះពុទ្ធ,

២- ធម្មានុស្សតិ រឭកដល់គុណព្រះធម៌,

៣- សង្ឃានុស្សតិ        រឭកដល់គុណព្រះសង្ឃ,

៤- សីលានុស្សតិ        រឭកដល់សីលរបស់ខ្លួន,

៥- ចាគានុស្សតិ        រឭកដល់ទានដែលខ្លួនបរិច្ចាគហើយ,

៦- ទេវតានុស្សតិ        រឭកដល់គុណធម៌ដែលធ្វើបុគ្គលឱ្យជាទេវតា

៧- មរណស្សតិ        រឭកដល់សេចក្ដីស្លាប់ដែលនឹងមានដល់ខ្លួន,

៨- កាយគតាសតិ        រឭកទូទៅក្នុងកាយឱ្យឃើញថា ជារបស់មិនស្អាតគួរខ្ពើម,

៩- អានាបានស្សតិ        តាំងសតិកំណត់ដង្ហើមចេញចូល,

១០- ឧបសមានុស្សតិ        រឭកដល់ព្រះនិព្វានជាទីរម្ងាប់កិលេសនិងកងទុក្ខ ។

## ពួកករាយរង

## សម្បត្តិទិព្វ ១០ យ៉ាង

១- អាយុទិព្វ,        ២- សម្បត្តិទិព្វ,

៣- សេចក្ដីសុខទិព្វ,        ៤- យសទិព្វ,

៥- អធិបតិទិព្វ,        ៦- រូបទិព្វ,

៧- សំលេងទិព្វ,        ៨- ខ្លិនទិព្វ,

៩- រសទិព្វ, ១០- សម្ពស្សទិព្វ, ។

## សតិមាន ១០ យ៉ាង (៩)

១- ពុទ្ធានុស្សតិ,

២- ធម្មានុស្សតិ,

៣- សង្ឃានុស្សតិ,

៤- សីលានុស្សតិ,

៥- ចាគានុស្សតិ,

៦- ទេវតានុស្សតិ,

៧- មរណានុស្សតិ,

៨- កាយគតានុស្សតិ,

៩- អានាបាណានុស្សតិ,

១០- ឧបសមានុស្សតិ,

## អំពីសម្បជញ្ញៈ ចែកចេញមាន ៤ យ៉ាង

១- សត្ថកសម្បជញ្ញៈ ដឹងថាបានដែលមានប្រយោជន៍,

២- សប្បាយសម្បជញ្ញៈ ដឹងថាជាទីសប្បាយ,

៣- គោចរសម្បជញ្ញៈ ដឹងថាជាទីគោចរ,

៤- អសម្មោហសម្បជញ្ញៈ ដឹងថាជាទីមិនវង្វេង ។

## បារមី ១០

១ ទាន, ៦- ខន្តី,

២- សីល, ៧- សច្ចៈ,

៣- នេក្ខម្ម, ៨- អធិដ្ឋាន,

៤- បញ្ញា, ៩- មេត្តា,

៥- វិរិយៈ, ១០- ឧបេក្ខា,

បារមីទាំង ១០ នេះក្នុងមួយ ចែកជា ៣ គឺទានបារមី ១, ទានឧប-បារមី១, ទានបរមត្ថបារមី១, ។ បញ្ចូលបារមីខាងមុខគ្រប់ៗ បទ ត្រូវជា ៣០ ។

## ជម្រៅនៃបិដកទាំង ៣ គឺ

១- ព្រះសូត្រ អត្ថគម្ភីរោ ជ្រៅដោយអត្ថ,

២- ព្រះវិន័យ វិនយោកិច្ចគម្ភីរោ ជ្រៅដោយកិច្ច,

៣- ព្រះអភិធម្ម អភិធម្មសភាវោ ជ្រៅដោយសភាវៈ បានដល់ចិត្ត, ចេតសិក, រូប, និព្វាន ។

## អានិសង្ស មេត្តា ១១ យ៉ាង

១- សុខំសុបតិ ដេកលក់ស្រួល,

២- សុខំបដិពុជ្ឈតិ ភ្ញាក់ឡើងស្រួល,

៣- នបាបកំសុបិនស្សតិ មិនយល់សប្តិឃើញអាក្រក់,

៤- មនុស្សានំ បិយោហោតិ ជាទីស្រលាញ់នៃមនុស្សទាំងឡាយ,

៥- អមនុស្សានំ បិយោហោតិ ជាទីស្រលាញ់នៃខ្មោចទាំងឡាយ,

៦- ទេវតារក្ខន្តិ ទេវតាទាំងឡាយតែងរក្សានូវបុគ្គលនោះ,

៧- នាស្សអគ្គិវាវិសំវាសត្ថំវាកសតិ ភ្លើងក្តីថ្នាំពិសក្តីមាំវិតក្តីមិនអាចប៉ះកាយនៃបុគ្គលនោះ ,

៨- តុវដំចិត្តំសមាធិយតិ ចិត្តនៃបុគ្គលនោះដំកល់ខ្ជាប់ដោយ-រហ័សឆាប់,

៩- មុខវណ្ណោវិប្បស្សីទតិ សប្បុរនៃបុគ្គលនោះជ្រះស្រឡះ,

១០- អសម្មុឡ្ហោកាលំករោតិ លុះដល់ធ្វើមរណៈកាលនឹងមិនវង្វេង,

១១- ឧត្តរឹអប្បដិវិជ្ឈន្តោព្រហ្មលោកបនោហោតិ ថាបើមិនទាន់ត្រាស់ដឹងនូវឧត្តរធម៌ ក៏គង់ស្ទាប់ទៅចូលទៅដល់នូវព្រហ្ម-លោកពុំខានឡើយ ។

## ៣.ការាយរង

## ឧប្បក្កិលេស ទោសជាគ្រឿងសៅហ្មង ១៦ យ៉ាង

១- អភិជ្ឈាវិសមលោភៈ លោភមិនស្មើគឺគយគន់រំពៃចង់បាន

មិនរើសមុខ,

| | |
|---|---|
| ១- ទោសៈ | គិតប្រទុស្ត, |
| ៣- កោធៈ | ក្រោធ, |
| ៤- ឧបនាហៈ | ចង់ក្រោធទុក, |
| ៥- មក្ខៈ | រមិលគុណគេ, |
| ៦- បលាសៈ | ធ្វើខ្លួនស្មើគឺលើកខ្លួនផ្ទឹមនឹងអ្នកខ្ពង់ខ្ពស់, |
| ៧- ឥស្សា | ឫស្សា គឺសេចក្តីប្រណែនឈ្នានីស, |
| ៨- មច្ឆរិយៈ | កំណាញ់, |
| ៩- មាយា | មាយាគឺលាក់ពុត ឬ ថាបិទបាំងទោសខ្លួន, |
| ១០- ថម្ភៈ | មុខរឹង, |
| ១២- សារម្ភៈ | ប្រណាំងវាសនា, |
| ១៣- មានៈ | ប្រកាន់ខ្លួន, |
| ១៤- អតិមានៈ | មើលងាយគេ, |
| ១៥- មទៈ | ស្រវឹង, |
| ១៦- បមាទៈ | ប្រហែសធ្វេស, |

# ពោធិបក្ខិយធម៌ ៣៧ ប្រការ

(មានហើយ)

| | | | |
|---|---|---|---|
| សតិប្បដ្ឋាន | ៤ | ទំព័រ | ៣២ |
| សម្មប្បធាន | ៤ (បធាន ៤) | ទំព័រ | ២៩ |
| ឥទ្ធិបាទ | ៤ | ទំព័រ | ៣០ |
| ឥន្ទ្រីយ៍ | ៥ | ទំព័រ | ៤០ |
| ពលៈ | ៥ | ទំព័រ | ៤០ |
| ពោជ្ឈង្គ | ៧ | ទំព័រ | ៦៦ |
| មគ្គមានអង្គ | ៨ | ទំព័រ | ៧៧ |

ធម៌ ៣៧ ប្រការ ដែលមាននាមថាពោធិបក្ខិយនោះ ព្រោះជាធម៌ផ្នែកខាងការត្រាស់ដឹង នូវកាលដែលព្រះបរមសាស្តារបស់យើងទាំងឡាយ បានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ គឺព្រះប្រាជ្ញាជាគ្រឿងត្រាស់ដឹងព្រះអង្គឯងដោយប្រពៃនោះ ព្រោះព្រះអង្គបានត្រាស់ដឹងនូវធម៌ ៣៧ ប្រការនេះឯង, ដែលជាតួអនុត្តរសម្មាសម្ពោធិញ្ញាណជាអនស្សុតធម៌ គឺធម៌ដែលព្រះអង្គមិនធ្លាប់បានឮ បានស្តាប់មកពីដើមឡើយ ស្រាប់តែកើតប្រាកដឡើងដល់ព្រះអង្គជាគ្រាដំបូង។ ធម៌ ៣៧ប្រ-ការនេះហើយ ដែលធ្វើព្រះអង្គឱ្យខ្វាយទៅជាព្រះសម្មាសម្ពុទ្ធពិតប្រាកដ

## ធម៌របស់គ្រហស្ថ

## បតុក្កៈ ពួក ៤

## កម្មក្កិលេស កម្មជាគ្រឿងសៅហ្មង ៤ យ៉ាង

១- បាណាតិបាត ធ្វើជីវិតសត្វឱ្យធ្លាក់ចុះ,

២- អទិន្នាទាន កាន់យករបស់ដែលគេមិនបានឱ្យ,

៣- កាមេសុមិច្ឆាចារ ប្រព្រឹត្តខុសក្នុងកាម,

៤- មុសាវាទ និយាយកុហក ។

កម្ម ៤ យ៉ាងនេះអ្នកប្រាជ្ញលោកជៀសវាងជានិច្ច ។

## អបាយមុខ ហេតុជាគ្រឿងវិនាស ៤ យ៉ាង

១- ឥត្ថីធុត្ត ជាអ្នកលេងស្រី,

២- សុរាធុត្ត ជាអ្នកលេងស្រា,

៣- អក្ខធុត្ត ជាអ្នកលេងល្បែងភ្នាល់ឬល្បែងស៊ីសង,

៤- បាបមិត្ត យកមនុស្សអាក្រក់ជាមិត្រ ។

## ទិដ្ឋធម្មិកត្ថ ប្រយោជន៍ក្នុងបច្ចុប្បន្ន ៤ យ៉ាង

១- ឧដ្ឋានសម្បទា ដល់ព្រមដោយសេចក្តីព្យាយាម គឺ

ព្យាយាមក្នុងការប្រកបកិច្ចចិញ្ចឹមជីវិតក្តី ក្នុងការសិក្សារៀនសូត្រក្តី ក្នុងកិច្ចធុរៈជាមុខការនាទីរបស់ខ្លួនក្តី,

២- អារក្ខសម្បទា ដល់ព្រមដោយការរក្សា គឺរក្សាទ្រព្យដែលរកបានមកដោយសេចក្តីព្យាយាម មិនឱ្យអន្តរាយទៅក្តី រក្សាការងារមិនឱ្យសាបសូន្យទៅក្តី,

៣- កល្យាណមិត្តតា ភាពជាអ្នកមានមិត្តល្អ មិនសេពគប់មិត្តអាក្រក់,

៤- សមជីវិតា ការចិញ្ចឹមជីវិតតាមសមគួរ ដល់កម្លាំងទ្រព្យដែលរកបានមក គឺមិនត្បិតត្បៀតពេក មិនខ្ជះខ្ជាយពេក ។

## សម្បរាយិកត្ថ ប្រយោជន៍បរលោក ៤ យ៉ាង

១- សទ្ធាសម្បទា ដល់ព្រមដោយសទ្ធា គឺជឿរបស់ដែលគួរជឿ ដូចជឿថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម,

២- សីលសម្បទា ដល់ព្រមដោយសីល គឺរក្សាកាយវាចាឱ្យរៀបរយ ឱ្យផុតចាកទោស,

៣- ចាគសម្បទា ដល់ព្រមដោយការបរិច្ចាគទាន ជាការចែកសុខដល់អ្នកដទៃ,

៤- បញ្ញាសម្បទា ដល់ព្រមដោយបញ្ញា គឺស្គាល់បាបបុណ្យគុណទោសប្រយោជន៍ និង ឥតប្រយោជន៍ជាដើម ។

# មិត្តដែលមិនគួរសេពគប់មាន ៤ ប្រភេទ

១- អញ្ញទត្ថុហរៈ មនុស្សឃើញតែខាងបានអំពីគេ,

២- វចីបរមៈ មនុស្សល្អតែមាត់,

៣- អនុប្បិយភាណី មនុស្សប្រចុប,

៤- អបាយសហាយ មនុស្សដឹកនាំក្នុងផ្លូវវិនាស,។

មនុស្ស ៤ ពួកនេះ ហៅថា មិត្តប្បដិរូបៈ មនុស្សប្លមជាមិត្រ ឬ មិត្រប្លម មិនមែនមិត្រប្រាកដទេ ។

១- អញ្ញទត្ថុហរៈ មនុស្សឃើញតែខាងបានអំពីគេ,

មានលក្ខណៈ ៤យ៉ាង

ក) គិតតែពីខាងបាន,

ខ) ឱ្យតិចចង់បានច្រើន,

គ) កាលមានភ័យដល់ខ្លួន ទើបជួយធ្វើកិច្ចការរបស់មិត្រ,

ឃ) សេពគប់នឹងមិត្រ ព្រោះតែឃើញប្រយោជន៍ខ្លួនឯង ។

២- វចីបរមៈ មនុស្សល្អតែមាត់ មានលក្ខណៈ ៤ យ៉ាង,

ក) រើសយករឿងហេតុ ដែលកន្លងទៅហើយមកពណ៌នា,

ខ) អាងយករឿងហេតុដែលមិនទាន់មានមកពណ៌នា,

គ) សង្គ្រោះដោយរបស់ឥតប្រយោជន៍,

ឃ) កាលមានកិច្ចកើតឡើង ពឹងប្រស្រ័យពុំបាន ។

៣- អនុប្បិយភាណី មនុស្សប្រចុប មានលក្ខណៈ ៤យ៉ាង

ក) មិត្រធ្វើអាក្រក់ក៏បណ្តោយតាម,

ខ) មិត្រធ្វើល្អក៏បណ្តោយតាម,

គ) ចំពោះមុខសរសើរ,

ឃ) កំបាំងមុខនិន្ទា,

៤- អាចាយសហាយ មនុស្សដឹកនាំក្នុងផ្លូវវិនាស,

**មានលក្ខណៈ ៤ យ៉ាង;**

ក) ដឹកនាំឱ្យផឹកទឹកស្រវឹង,

ខ) ដឹកនាំឱ្យដើរលេងយប់,

គ) ដឹកនាំឱ្យចូលចិត្តលេង ឬមើលមហោស្រព,

ឃ) ដឹកនាំឱ្យលេងល្បែងភ្នាល់ ឬល្បែងស៊ីសង ។

## មិត្រដែលគួរសេពគប់មាន ៤ ប្រភេទ

១- ឧបការមិត្ត មិត្រមានឧបការៈ,

២- សុខទុក្ខមិត្ត មិត្ររួមសុខទុក្ខ,

៣- អត្ថក្ខាយិមិត្ត មិត្រប្រាប់ផ្លូវប្រយោជន៍ឱ្យ,

៤- អនុកម្បកមិត្ត មិត្រមានសេចក្ដីអាណិត ។

១- ឧបការមិត្ត    មិត្រមានឧការៈ,

មានលក្ខណៈ ៤ យ៉ាង

ក) ការពារមិត្រដែលប្រហែសហើយ,

ខ) ការពារទ្រព្យរបស់មិត្រដែលប្រហែសហើយ,

គ) កាលមានភ័យយកជាទីពឹងបាន,

ឃ) កាលមានធុរៈកើតឡើងជួយចេញទ្រព្យ លើសជាងមិត្រ,

និយាយខ្ទី ។

២- សុខទុក្ខមិត្ត មិត្ររួមសុខរួមទុក្ខ មានលក្ខណៈ ៤ យ៉ាង

ក) បញ្ចេញសេចក្ដីកំបាំងរបស់ខ្លួនប្រាប់ដល់មិត្រ,

ខ) បិទសេចក្ដីកំបាំងរបស់មិត្រមិនឱ្យសាយភាយ,

គ) មិនលះចោលគ្នាក្នុងកាលមានភ័យអន្តរាយ,

ឃ) សូម្បីជីវិតក៏លះជំនួសបាន,

៣- អត្ថក្ខាយិមិត្ត មិត្រប្រាប់ផ្លូវប្រយោជន៍ឱ្យ

មានលក្ខណៈ ៤យ៉ាង

ក) ហាមមិនឱ្យធ្វើសេចក្ដីអាក្រក់,

ខ) ដឹកនាំឱ្យតាំងនៅក្នុងសេចក្ដីល្អ,

គ) ដឹកនាំឱ្យបានស្តាប់សេចក្តីដែលមិនទាន់បានស្តាប់,

ឃ) ប្រាប់ផ្លូវសួគ៌ឱ្យស្គាល់ ។

៤- អនុកម្បកមិត្ត មិត្រមានសេចក្តីអាណិត,

មានលក្ខណៈ ៤យ៉ាង

ក) មិនត្រេកអរក្នុងវេលាមិត្រសាបសូន្យ,

ខ) ត្រេកអរចំពោះមិត្រអ្នកបានសេចក្តីចំរើន,

គ) ហាមឃាត់មនុស្សអ្នកនិយាយតិះដៀលមិត្រ,

ឃ) សរសើរមនុស្សអ្នកនិយាយលើកមិត្រ ។

## ការបែងទ្រព្យជាបំណែក ៤

គ្រហស្ថអ្នករកទ្រព្យបានមកគប្បីបែងចែកជាចំណែក ៤

១- ឱ្យសងបំណុលចាស់ បានដល់ទំនុកបម្រុងមាតាបិតា,

២- បុលបំណុលថ្មី បានដល់ទំនុកបម្រុងចិញ្ចឹមកូន,

៣- បោះក្នុងជ្រោះជ្រៅ បានដល់ការចាយវាយប្រើប្រាស់ក្នុងគ្រួសារ និងបង់ពន្ធអាករាជការជាដើម,

៤- ឱ្យកប់ទុកជាកំណប់ព្រេង បានដល់ការធ្វើបុណ្យទានសម្រាប់ជីវិតទៅបរលោក ។

កាលបើគ្រហស្ថបែងទ្រព្យបានយ៉ាងនេះរមែងបានសេចក្តីសុខចំរើន ។

## សង្គហវត្ថុ ៤យ៉ាង

១- ទានៈ បែងវត្ថុរបស់ខ្លួនឱ្យដល់បុគ្គលដែលគួរឱ្យ,

២- បិយវាចា ពោលវាចាពីរោះជាទីស្រលាញ់,

៣- អត្ថចរិយា ប្រព្រឹត្តក្នុងការជាប្រយោជន៍ដល់អ្នកដទៃ,

៤- សមានត្តតា ជាអ្នកតាំងខ្លួនស្មើ មិនប្រកាន់ខ្លួន ។

គុណធម៌ ៤ យ៉ាងនេះជាគ្រឿងទាញចិត្តអ្នកដទៃឱ្យរាប់អានខ្លួន ។

## សុខរបស់គ្រហស្ថ ៤ យ៉ាង

១- សុខកើតអំពីការមានទ្រព្យ,

២- សុខកើតអំពីការចាយទ្រព្យបរិភោគ,

៣- សុខកើតអំពីការមិនជំពាក់បំណុលគេ,

៤- សុខកើតអំពីការប្រកបការងារប្រាសចាកទោស,

## សេចក្តីប្រាថ្នារបស់បុគ្គលក្នុងលោក ដែលបានដោយកម្រមាន ៤ យ៉ាង

១- សូមឱ្យសម្បត្តិកើតមានដល់អាត្មាអញដោយផ្លូវប្រពៃ,

២- សូមឱ្យយសកើតមានដល់អាត្មាអញនិងញាតិរបស់អាត្មាអញ,

៣- សូមឱ្យអាត្មាអញមានអាយុវែង,

៤- កាលបើអាត្មាអញអស់ជីវិតទៅ សូមឱ្យកើតក្នុងស្ថានសួគ៌ ។

## ធម៌ដែលជាហេតុឱ្យបានសម្រេចផល

## ដូចសេចក្ដីប្រាថ្នា ៤ យ៉ាង

១- សទ្ធាសម្បទា ដល់ព្រមដោយសទ្ធា,

២- សីលសម្បទា ដល់ព្រមដោយសីល,

៣- ចាគសម្បទា ដល់ព្រមដោយការបរិច្ចាគទាន,

៤- បញ្ញាសម្បទា ដល់ព្រមដោយបញ្ញា ។

## ត្រកូលស្ដុកស្ដម្ភដែលតាំងនៅយូរមិនបាន

## ព្រោះស្ថានធម៌ ៤ យ៉ាង

១- មិនស្វែងរករបស់ដែលបាត់ទៅហើយ,

២- មិនជួសជុលរបស់ដែលចាស់គ្រាំគ្រា,

៣- មិនដឹងប្រមាណក្នុងការចាយប្រើទ្រព្យធន់,

៤- តាំងស្ត្រីឬបុរសទ្រុស្តសីលឱ្យជាមេផ្ទះ,

អ្នកដែលចង់ឱ្យត្រកូលគង់វង្សនៅយូរត្រូវលះវៀរស្ថាន ៤ យ៉ាងនេះចេញ ។

# ធម៌របស់ឃរាវាស ៤ យ៉ាង

១- សច្ចៈ ពិតត្រង់ដល់គ្នានឹងគ្នា,

២- ទមៈ ទូន្មានចិត្ត,

៣- ខន្តិ សេចក្តីអត់ធន់,

៤- ចាគៈ លះបែកវត្ថុរបស់ខ្លួនដល់បុគ្គលដែលគួរឱ្យ ។

ដំណឹងសៀវភៅចេញថ្មី

សៀវភៅធាតុសង្គ្រោះ ដោយការរៀបរៀងរបស់ អ៊ុម-គយ អតីតក្រុមជំនុំព្រះត្រៃបិដក, មានចេញលក់ហើយ ។

## បញ្ញាគៈពួក ៥

# ការប្រើប្រាស់ទ្រព្យសម្បត្តិដោយស្គាល់ធម៌ ៥ យ៉ាង

អ្នកដែលរកទ្រព្យបានមកដោយផ្លូវដ៏ល្អហើយត្រូវប្រើប្រាស់យ៉ាងនេះគឺ:

១- ចិញ្ចឹមខ្លួននិងមាតាបិតា បុត្រភរិយា ទាសកម្មករឱ្យជាសុខ,

២- ចិញ្ចឹមមិត្រសម្លាញ់ឱ្យជាសុខ,

៣- បំបាត់អន្តរាយដែលកើតអំពីហេតុផ្សេងៗ,

៤- ធ្វើពលី ៥ យ៉ាងគឺ ៖

ក) ញាតិពលី សង្គ្រោះញាតិ,

ខ) អតិថិពលី ទទួលភ្ញៀវ,

គ) បុព្វបេត្តពលី ធ្វើបុណ្យឧទ្ទិសផលដល់អ្នកដែលចែកឋានទៅហើយ,

ឃ) រាជពលី ថ្វាយសួយសារអាករដល់ម្ចាស់ផែនដី (ពន្ធដារ)

ង) ទេវតាពលី កាលណាធ្វើបុណ្យ ឧទ្ទិសផលដល់ទេវតាផង ។

៥- បរិច្ចាគទានដល់សមណព្រាហ្មណ៍អ្នកប្រព្រឹត្តល្អ ។

## សីល ៥

១- បាណាតិបាតា វេរមណី វៀរចាកធ្វើជីវិតសត្វឱ្យធ្លាក់ចុះ,

២- អទិន្នាទានា វេរមណី	វៀរចាកកាន់យកទ្រព្យដែលម្ចាស់គេមិនបានឱ្យ,

៣- កាមេសុមិច្ឆាចារា វេរមណី វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ,

៤- មុសាវាទា វេរមណី	វៀរចាកនិយាយកុហក,

៥- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី វៀរចាកផឹកទឹកស្រវឹង គឺសុរានិងមេរ័យដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ ។

សីល៥ នេះគ្រហស្ថគួររក្សាជានិច្ច ទើបបរិបូណ៌ដោយសេចក្ដីចម្រើនសមតាមបំណង ។

## កល្យាណធម៌

ធម៌ដែលល្អហៅថាកល្យាណធម៌មាន ៥ យ៉ាង

១- មេត្តាចិត្តគិតចង់ឱ្យគេបានសុខ និងករុណាចង់ឱ្យគេប្រាស់ចាកទុក្ខ,

២- សម្មាអាជីវៈ	ចិញ្ចឹមជីវិតប្រពៃ,

៣- សទារសន្តោសៈ សន្តោសគឺត្រេកអរចំពោះភរិយារបស់ខ្លួន,

៤- សច្ចៈ	ប្រព្រឹត្តខ្លួនជាមនុស្សស្មោះត្រង់,

៥- សតិ	មានស្មារតីបរិបូណ៌ ។

## កល្យាណធម៌ ៥ យ៉ាងនេះជាគូគ្នានឹងសីល ៥ គឺ:

១- មេត្តា ជាគូនឹងបាណាតិបាត,

២- សម្មាអាជីវ: ជាគូនឹងអទិន្នាទាន,

៣- សទារសន្តោស: ជាគូនឹងកាមេសុមិច្ឆាចារ:,

៤- សច្ច: ជាគូនឹងមុសាវាទ,

៥- សតិ ជាគូនឹងសុរាមេរយ: ។

កល្យាណធម៌ ៥យ៉ាងនេះ ត្រូវបំពេញឱ្យបរិបូណ៌ដើម្បីធ្វើសីល៥ ឱ្យបរិសុទ្ធ ។

## មិច្ឆាវណិជ្ជា ការលក់ដូរខុសធម៌ ៥ យ៉ាង

១- សត្ថវណិជ្ជា លក់គ្រឿងប្រហារ,

២- សត្តវណិជ្ជា លក់មនុស្ស,

៣- មំសវណិជ្ជា លក់សត្វរស់ដែលគេនឹងសម្លាប់យកសាច់,

៤- មជ្ជវណិជ្ជា លក់ទឹកស្រវឹង,

៥- វិសវណិជ្ជា លក់ថ្នាំពិស,

ការលក់ដូរ ៥យ៉ាងនេះគឺ ឧបាសក ឧបាសិកាមិនត្រូវធ្វើទេ ។

# សម្បត្តិរបស់ឧបាសក ៥ យ៉ាង

១- ប្រកបដោយសទ្ធា,

២- មានសីលបរិសុទ្ធ,

៣- មិនភ្ញាក់ផ្អើលដោយមង្គល គឺជឿកម្ម មិនជឿមង្គលភ្ញាក់ផ្អើល,

៤- មិនស្វែងរកខេត្តបុណ្យក្រៅព្រះពុទ្ធសាសនា,

៥- បំពេញបុណ្យតែក្នុងព្រះពុទ្ធសាសនា,

ឧបាសកត្រូវតាំងនៅក្នុងសម្បត្តិ ៥ យ៉ាងនេះ ត្រូវវៀរចាកវិបត្តិ ៥ យ៉ាងដែលជាទំនាស់នឹងសម្បត្តិនេះចេញ ។

# ឆក្កៈពួក ៦

# ទិស ៦

| | | | |
|---|---|---|---|
| ១- បុរត្ថិមទិស | ទិសបូព៌ | ទុកជាមាតាបិតា | (ខាងកើត) |
| ២- ទក្ខិណទិស | ទិសទក្សិណ | ទុកជាគ្រូបាអាចារ្យ | (ខាងត្បូង) |
| ៣- បច្ឆិមទិស | ទិសបស្ចិម | ទុកជាភរិយា | (ខាងលិច) |
| ៤- ឧត្តរទិស | ទិសឧត្តរ | ទុកជាមិត្រ | (ខាងជើង) |
| ៥- ហេដ្ឋិមទិស | ទិសខាងក្រោម | ទុកជាទាសកម្មករ, | |
| ៦- ឧបរិមទិស | ទិសខាងលើ | ទុកជាសមណព្រាហ្មណ៍ ។ | |

## ១- បុរិត្ថិមទិសទុកជាមាតាបិតា

បុត្រធីតាត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាងគឺ

ក) ភតោ នេសំ ករិស្សាមិ — លោកបានចិញ្ចឹមខ្លួនមកហើយ ត្រូវចិញ្ចឹមលោកវិញ,

ខ) កិច្ចំ នេសំ ករិស្សាមិ — ធ្វើកិច្ចការរបស់លោក,

គ) កុលវំសំ ឋបេស្សាមិ — ទំនុកបម្រុងវង្សត្រកូលមិនឱ្យសាបសូន្យ

ឃ) ទាយជ្ជំ បដិបជ្ជាមិ — ប្រតិបត្តិឱ្យសមគួរជាអ្នកទទួលមត៌ក,

ង) ទក្ខិណំ អនុប្បទស្សាមិ — កាលបើលោកធ្វើកាលកិរិយាទៅហើយ ត្រូវធ្វើបុណ្យឧទ្ទិសផលជូនទៅលោក ។

## មាតាបិតាត្រូវសង្គ្រោះបុត្រធីតា
## ដោយស្ថានធម៌ ៥ យ៉ាង

ក) បាបានិវារេន្តិ ហាមមិនឱ្យធ្វើសេចក្តីអាក្រក់,

ខ) កល្យាណេនិវេសេន្តិ ឱ្យតាំងនៅក្នុងសេចក្តីល្អ,

គ) សិប្បំ សិក្ខាបេន្តិ ឱ្យសិក្សាសីលវិជ្ជា,

ឃ) បដិរូបេន ទារេន សំយោជេន្តិ រៀបចំកូនឱ្យមានផ្ទះសំបែង,

ង) សមយេទាយជ្ជំ និយ្យាទេន្តិ ប្រគល់ទ្រព្យមត៌កឱ្យក្នុងសម័យដ៏គួរ ។

## ២- ទក្ខិណទិស ទុកជាគ្រូបាអាចារ្យ

### សិស្សត្រូវប្រតិបត្តិដោយស្ថានធម៌ ៥ យ៉ាង

ក) ឧដ្ឋានេន ក្រោកឈរទទួលក្នុងវេលាដែលគ្រូបាអាចារ្យដើរមក,

ខ) ឧបដ្ឋានេន ចូលទៅចាំបម្រើលោក,

គ) សុស្សុសាយ ជឿស្តាប់ឱវាទលោក,

ឃ) បារិចរិយាយ ឧបដ្ឋាកបម្រើលោក,

ង) សក្កច្ចំ សិប្បំ ដិគ្គហណេន រៀនសិល្បវិជ្ជាដោយគោរព ។

## គ្រូបាអាចារ្យត្រូវអនុគ្រោះសិស្សដោយស្ថានធម៌ ៥ យ៉ាង

ក) សុវិនីតំ វិនេន្តិ ណែនាំឱ្យល្អ,

ខ) សុគហិតំគាហានបេន្តិ ឱ្យរៀនល្អ,

គ) សព្វសិប្បេសុតំសមក្ខាយិនោ ភវន្តិ ប្រាប់សិល្បវិជ្ជាឱ្យអស់ចំ-
ណេះមិនលាក់ទុក,

ឃ) មិត្តាមច្ចេសុ បដិវេទន្តិ លើកតម្កើងក្នុងទីចំពោះមុខមិត្រអាមាត្យ,

ង) ទិសាសុ បរិត្តានំ ករោន្តិ ធ្វើសេចក្តីការពារ ក្នុងទិសទាំងឡាយ
គឺសិស្សទៅក្នុងទីណាមិនឱ្យលំបាក ។

## ៣- បច្ឆិមទិស ទុកជាភរិយា

ស្វាមីត្រូវទំនុកបម្រុងដោយស្ថានធម៌ ៥ យ៉ាង

ក) សម្មាននាយៈ រាប់អានលើកមុខថាជាភរិយា,

ខ) អវិមាននាយៈ មិនមើលងាយ,

គ) អនតិចរិយាយៈ មិនប្រព្រឹត្តកន្លងចិត្ត គឺមិនក្បត់ចិត្តភរិយា,

ឃ) ឥស្សរិយវោស្សគ្គេន ប្រគល់ភារៈជាធំក្នុងផ្ទះឱ្យ,

ង) អលង្ការានុប្បទានេន ឱ្យគ្រឿងតែងខ្លួន ។

## ភរិយាត្រូវប្រតិបត្តិស្វាមីដោយស្ថានធម៌ ៥ យ៉ាង

ក) សុសំវិហិតកម្មន្តា ចាត់ចែងការងារដោយល្អ,

ខ) សុសង្គហិតបរិជនា សង្គ្រោះញាតិខាងស្វាមីដោយល្អ,

គ) អនតិចារនី មិនប្រព្រឹត្តកន្លងចិត្តស្វាមី គឺមិនក្បត់ចិត្តប្តី,

ឃ) សម្ភតញ្ច អនុរក្ខតិ រក្សាទ្រព្យដែលស្វាមីរកបានមក,

ង) ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ ឧស្សាហ៍មិនខ្ជិលក្នុងកិច្ចការទាំងពួង ។

## ៤- ឧត្តរទិស ទុកជាមិត្រ

កុលបុត្រទំនុកបម្រុងដោយស្ថានធម៌ ៥ យ៉ាង

ក) ទានេន ចែកចាយរបស់ដែលសមគួរឱ្យ,

ខ) បិយវជ្ជេន ពោលពាក្យពីរោះទៅរក,

គ) អត្ថបរិយាយ ប្រព្រឹត្តប្រយោជន៍ឱ្យ,

ឃ) សមានត្តតាយ ជាអ្នកមានខ្លួនស្មើនឹងមិត្រ,

ង) អវិសំវាទនតាយ មិនខ្វែងពោលឱ្យឃ្លាតចាកសេចក្តីពិតត្រង់,

## មិត្រត្រូវទំនុកបម្រុងកុលបុត្រ ដោយស្ថានធម៌ ៥ យ៉ាង

ក) បមត្តំ រក្ខន្តិ រក្សាមិត្រអ្នកប្រហែសធ្វេស,

ខ) បមត្តស្ស សាបតេយ្យំ រក្ខន្តិ រក្សាទ្រព្យសម្បត្តិរបស់មិត្រអ្នកប្រហែសធ្វេស,

គ) កីតស្ស សរណំ ហោន្តិ កាលបើមិត្រមានភ័យហើយយក ជាទីពឹងពុំនាក់បាន,

ឃ) អាបទាសុ ន វិជហន្តិ មិនលះចោលមិត្រក្នុងវេលាមានទុក្ខ,

ង) អបរបជំបិស្ស បដិបូជេន្តិ រាប់អានមិត្ររហូតដល់វង្សត្រកូលរបស់មិត្រ។

## ៥- ហេដ្ឋិមទិស ទុក្ខជាទាសកម្មករ

ចៅហ្វាយនាយត្រូវទំនុកបម្រុងដោយស្ថានធម៌ ៥ យ៉ាង

ក) យថាពលំ កម្មន្តំ សំវិធានេន ចាត់ចែងការងារឱ្យធ្វើ តាមសមគួរដល់កម្លាំង,

ខ) ភត្តវេត្តនានុប្បទានេន ឱ្យភោជនាហារនិងរង្វាន់,

គ) គិលានុប្បដ្ឋានេន ព្យាបាលក្នុងវេលាមានជម្ងឺ,

ឃ) អរិយានំ រសានំ សំវិភាគេន ចែកភោជនាហារដែលមាន ឱជារសប្លែកៗ ឱ្យបរិភោគ,

ង) សមយេ វោស្សគ្គេន បើកឱ្យសប្បាយក្នុងកាលគួរ ។

## ទាសកម្មករត្រូវប្រតិបត្តិចៅហ្វាយនាយ ដោយស្ថានធម៌ ៥ យ៉ាង

ក) បុព្វដ្ឋានយិនោ ច ហោន្តិ ក្រោកឡើងធ្វើការងារមុន

ចៅហ្វាយនាយ,

ខ) បច្ឆានិបាតិនោ          លែងធ្វើការងារក្រោយចៅហ្វាយនាយ,

គ) ទិន្នាទាយិនោ          កាន់យកតែរបស់ដែលចៅហ្វាយនាយឱ្យ

ឃ) សុកតកម្មការោ          ធ្វើការងារដោយយកចិត្តទុកដាក់,

ង) កិត្តិវណ្ណហរា          នាំកិត្តិគុណរបស់ចៅហ្វាយនាយទៅពោលសរសើរក្នុងទីដទៃ ។

## ៦- ឧបរិមទិស ទុកជាសមណព្រាហ្មណ៍

## គ្រហស្ថត្រូវទំនុកបម្រុងដោយស្ថានធម៌ ៥ យ៉ាង

ក) មេត្តាកាយកម្ម          ធ្វើអ្វីៗប្រកបដោយមេត្តា,

ខ) មេត្តាវចីកម្ម          និយាយអ្វីៗប្រកបដោយមេត្តា,

គ) មេត្តាមនោកម្ម          គិតអ្វីៗប្រកបដោយមេត្តា,

ឃ) អនាវដទ្វារតាយៈ ជាអ្នកមិនបិទទ្វារ គឺពុំបានហាមមិនឱ្យចូលផ្ទះ

ង) អាមិសានុប្បទានេន          ផ្តល់អាមិសទានឱ្យ ។

## សមណព្រាហ្មណ៍ ត្រូវអនុគ្រោះគ្រហស្ថ

## ដោយស្ថានធម៌ ៦ យ៉ាង

ក) បាបា និវារេន្តិ          ដឹកនាំមិនឱ្យធ្វើអាក្រក់,

ខ) កល្យាណេ និវេសេន្តិ    ដឹកនាំឱ្យតាំងនៅក្នុងអំពើល្អ,

គ) កល្យាណេន មនសា អនុកម្បន្តិ    អនុគ្រោះដោយទឹកចិត្តល្អ,

ឃ) អសុតំ សាវេន្តិ    ឱ្យបានស្ដាប់ធម៌ដែលមិនធ្លាប់បានស្ដាប់,

ង) សុតំ បរិយោទេន្តិ    ពន្យល់ធម៌ដែលគេធ្លាប់បានស្ដាប់ហើយ ឱ្យរឹងរឹតតែយល់ច្បាស់ឡើង,

ច) សគ្គស្ស មគ្គំ អាចិក្ខន្តិ    ប្រាប់ផ្លូវឋានសួគ៌ឱ្យគេបានដឹង ។

## អបាយមុខ ហេតុដែលធ្វើឱ្យវិនាស ៦ យ៉ាង

១- មជ្ជបានៈ    ផឹកទឹកស្រវឹង,

២- វិកាលចរណៈ    ដើរលេងយប់ គឺដើរខុសកាល,

៣- សមជ្ជាភិចរណៈ    ដើរមើលល្បែងមហោស្រព,

៤- ជូតានុយោគៈ    លេងល្បែងភ្នាល់ ឬល្បែងស៊ីសង,

៥- បាបមិត្តានុយោគៈ    សេពគប់មនុស្សអាក្រក់ជាមិត្រ,

៦- អាលស្សានុយោគៈ    ខ្ជិលធ្វើការងារ ។

## ១- មជ្ជបានៈ ការផឹកទឹកស្រវឹងមានទោស ៦ យ៉ាង

ក) នាំឱ្យខូចខាតទ្រព្យ,

ខ) បង្កើតសេចក្ដីឈ្លោះទាស់ទែង,

គ) ជាអណ្តូងកើតរោគ,

ឃ) ញុំាងសេចក្តីនិន្ទាឱ្យកើតឡើង,

ង) ញុំាងកេរ្តិ៍ខ្មាស់ឱ្យប្រាកដមិនអៀនអន់,

ច) ធ្វើបញ្ញាឱ្យអន់ថយ ។

## ២-វិកាលចរណៈ ដើរលេងយប់មានទោស ៦ យ៉ាង

ក) មិនរក្សាខ្លួន,

ខ) មិនរក្សាកូនប្រពន្ធ,

គ) មិនរក្សាទ្រព្យសម្បត្តិ,

ឃ) ជាទីរង្កៀសរបស់មនុស្សទាំងឡាយ,

ង) ច្រើនតែគេត្រូវប្រកាន់ទោស,

ច) បានសេចក្តីលំបាកច្រើន ។

## ៣-សមជ្ជាភិចរណៈ ការដើរមើលល្បែងមហោស្រព

មានទោសតាមវត្ថុដែលទៅមើល ៦ យ៉ាង

ក) រាំនៅទីណាទៅកាន់ទីនោះ

ខ) ច្រៀងនៅទីណាទៅកាន់ទីនោះ,

គ) ដេញដំប្រគុំនៅទីណាទៅកាន់ទីនោះ,

ឃ) គេនិយាយលេងសើចនៅទីណាទៅកាន់ទីនោះ,

ង) ល្បែងច្រៀងទះដៃនៅទីណាទៅកាន់ទីនោះ,

ច) ពិណពាទ្យនាតគងនៅទីណាទៅកាន់ទីនោះ,

## ៤- ជូតានុយោគៈ ការលេងល្បែងភ្នាល់មានទោស ៦ យ៉ាង

ក) កាលឈ្នះរមែងបង្កឱ្យកើតពៀរ,

ខ) កាលចាញ់រមែងសោកស្ដាយទ្រព្យ,

គ ទ្រព្យរមែងវិនាស,

ឃ) មិនមានអ្នកណាមួយជឿពាក្យ,

ង) ជាទីមើលងាយរបស់មិត្រ,

ច) មិនមានអ្នកណាមួយត្រូវការនឹងបង់ពន្ធផង ។

## ៥- បាបមិត្តានុយោគៈ ការសេពគប់មនុស្សអាក្រក់ជាមិត្ត មានទោស ៦ យ៉ាង

ក) នាំឱ្យជាអ្នកលេងល្បែងភ្នាល់ ឬល្បែងស៊ីសង,

ខ) នាំឱ្យជាអ្នកលេងស្រី,

គ) នាំឱ្យជាអ្នកលេងស្រា,

ឃ) នាំឱ្យជាអ្នកបោកប្រាសគេដោយរបស់ក្លែងខ្លាយ,

ង) នាំឱ្យជាអ្នកបោកប្រាស់គេចំពោះមុខ,

ច) នាំឱ្យជាអ្នកលួចប្លន់ឆក់ដណ្តើមយកទ្រព្យគេ ។

## ៦- អាលស្សានុយោគៈ ការខ្ជិលធ្វើការងារមានទោស ៦ យ៉ាង

ក) អតិសីតំ អាងថារងាណាស់ ហើយមិនធ្វើការងារ,

ខ) អតិឧណ្ហំ អាងថាក្តៅណាស់ ហើយមិនធ្វើការងារ,

គ) អតិសាយំ អាងថាល្ងាចណាស់ ហើយមិនធ្វើការងារ,

ឃ) អតិបាតោ អាងថាព្រឹកណាស់ ហើយមិនធ្វើការងារ,

ង) អជិឃច្ឆាតោ អាងថាឃ្លានណាស់ ហើយមិនធ្វើការងារ,

ច) អតិបិបាសិតោ អាងថាស្រេកណាស់ ហើយមិនធ្វើការងារ ។

អ្នកដែលចង់បានសេចក្តីចំរើនដោយទ្រព្យសម្បត្តិ ត្រូវលះអបាយមុខ, ទាំង ៦ យ៉ាងនេះចេញ ។